អតីត និង បច្ចុប្បន្នភាព
របស់ជនរងគ្រោះពីការបង្ខំឲ្យរៀបការសម័យខ្មែរក្រហម

The Past and the Present
of Forced Marriage Survivors



ដំណើរឆ្ពោះទៅរកការសះជា
Experience toward Healing

-តុលា ២០១៦-

រូបភាពពីមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam)

រូបភាពឯកសារស្តីពីការបង្ខំឲ្យរៀបការក្នុងសម័យខ្មែរក្រហម

The archive of forced marriage in Khmer Rouge

មាតិកា
Content

ឧទ្ទិសជូន 3
Dedication 3
អារម្ភកថា 4
Foreword 5
សេចក្តីផ្តើម និងសាវតារឿង 6
Introduction and Background of Book 9
សេចក្តីថ្លែងអំណរគុណ 11
Acknowledgments 11
ប៉ែន សុខចាន់ 12
Ms. PEN Sokchan 14
ឡាយ គីមឈាន 16
Ms. LAY Kimchhean 18
ឌឿក សំ 22
Ms. DOEUK Sam 24
ហេង គុយឡាង 27
Ms. HENG Kuylang 29
អ៊ំ ងុន 32
Ms. OM Ngon 34
អ៊ំ យ៉ាន 37
Ms. OM Yan 39
រី ហុន 43
Ms. RY Hon 46
សន ភាព 49
Ms. SORN Pheap 51
អ្នកនិពន្ធ 52
Author 52

ឧទ្ទិសជូន

សៀវភៅនេះ នាងខ្ញុំសូមឧទ្ទិសជូនដល់ជនរងគ្រោះដែលបានស្លាប់ និងគោរពជូនដល់ជនរងគ្រោះ ដែលបានរស់នានមានជីវិតពីអំពើហិង្សាផ្លូវភេទនានាដែលបានកើតឡើងក្នុងសម័យខ្មែរក្រហម ។ សូមឲ្យវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់បានទៅកាន់សុគតិភព រៀវចាកផុតពីការឈឺចាប់ទាំងពួង ។ នាងខ្ញុំក៏សូមបន់ស្រន់ឲ្យអ្នកដែលនៅរស់ ពីអំពើហិង្សាផ្លូវភេទនោះឆាប់បាន ទទួលយុត្តិធម៌ចំពោះការបាត់បង់ និងការឈឺចាប់របស់ពួកគាត់ ។ ជាពិសេសនាងខ្ញុំសូមអំពាវនាវ និងលើកទឹកចិត្តដល់ក្រុមគ្រួសារគ្រប់រូប មិនថាជាក្រុមគ្រួសារដែលត្រូវបាន ឬមិនត្រូវបានបង្ខំឲ្យរៀបការដោយខ្មែរក្រហម សូមបញ្ឈប់អំពើហិង្សា ហើយបែរត្រឡប់មកជាការផ្តល់ការស្រឡាញ់ គាំទ្រគ្នាទៅវិញទៅមកវិញទើបប្រសើរ ។ សូមចាំថាអំពើហិង្សាបំផ្លាញអ្នក និងក្រុមគ្រួសារបស់ទាំងមូល ។

Dedication

I dedicate this book to all those who died and the survivors who suffered from all types of gender-based violence during the Khmer Rouge Regime. May the spirits of the dead stay in peace and free from suffering. I also pray for the survivors to find justice for their suffering soon.

I particularly call for and encourage couples, whether in forced marriages or not, to stop violence and turn to loving and supporting each other. Remember that violence destroys you and your family.

អារម្ភកថា

របបខ្មែរក្រហមបានដួលរំលំជាច្រើនទសវត្សរ៍មកហើយ ប៉ុន្តែនៅពេលគេរំឭកពីជីវិតនាសម័យនោះម្តង។ អ្នកដែលធ្លាប់រស់នៅក្នុងសម័យនោះ តែងតែមានការរំជួលចិត្តមិនអាចទប់ទឹកភ្នែក អូលដើមក និកពីអតីតកាលដ៏ជូរចត់ និងដ៏គួរឲ្យរន្ធត់ និងមិននឹកស្មានថាគេបានរស់រានមានជីវិតឆ្លងផុតពីរបបមហាប្រល័យនោះបានសោះ។ ដោយសាររឿងដែលគួររន្ធត់ជាងគេ គឺការបារម្ភពីជីវិតរបស់គេនោះ ប្រជាជនខ្មែរមិនដែលគិតពីអំពើហិង្សាលើស្ត្រី ឬ យេនឌ័រជារឿងសំខាន់នោះទេ ហើយសឹងតែមិនបាន រាប់ថាជាអំពើដែលស្ត្រីខ្មែរនៅពេលនោះរងទុក្ខដោយសារអំពើហិង្សាទាំងនោះទៀតផង។

អ្នករងគ្រោះជាស្ត្រីភេទ ត្រូវខ្មែរក្រហមរំលោភសពសន្ធវៈមុននឹងសម្លាប់តែមានមនុស្សតិចណាស់ដែលដឹងរឿងនេះ ព្រោះអ្នករងគ្រោះបានស្លាប់បាត់បង់ជីវិតទៅហើយ អ្នកដែលនៅរស់រានមានជីវិតរួចផុតមាត់មច្ចុរាជមានតិច ហើយគេមិនចង់រំឭកពីជីវិតដ៏រន្ធត់នោះបានទេ ហើយរំឭកឡើងក៏មិនដឹងជាជនល្មើសនៅទីណានរណាជាអ្នកទទួលខុសត្រូវ។ ស្ត្រីខ្លះត្រូវគេបង្ខំឲ្យរៀបការជាមួយនិងយោធាខ្មែរក្រហម ដែលពួកគេមិនស្រឡាញ់មានតែចិត្តស្អប់និងភ័យខ្លាច ប៉ុន្តែគេយល់ថាតាមទំនៀមទម្លាប់នេះគឺជារឿងធម្មតា ជាវាសនាដែលពួកនាងត្រូវតែទទួល។ បុរសភាគច្រើនត្រូវបានសម្លាប់តែស្ត្រីជាច្រើនត្រូវឆ្លងកាត់ ជីវិតដ៏សែនរន្ធត់នាសម័យនោះទៅវិញ។ ពួកគេរស់ដោយនឹករលឹក និងសោកស្តាយស្ទាមី កូនដែលត្រូវខ្មែរក្រហមយកទៅសម្លាប់គេយើញកូនរបស់គេ ដែលគេតែងតែថ្នាក់ថ្នមរស់នៅដោយ អត់ឃ្លាន ធ្វើការជាទម្ងន់ គ្មានពេលសម្រាក និងគ្មានអ្វីទទួលទាន។ ស្ត្រីខ្មែរក្រហមក៏មានមិនតិចណាស់ទេ ដែលកម្មាភិបាលចាប់រំលោភ រួចរកលេសចាប់ក៏ហុស ហើយសម្លាប់ចោល។

រឿងទាំងអស់ដែលបានកើតឡើងនាសម័យនោះ មិនត្រូវឲ្យកើតមានតទៅទៀតបានទេ។ ដូចនេះសៀវភៅនេះមានសារៈសំខាន់សម្រាប់ឲ្យក្មេងជំនាន់ក្រោយឲ្យបានដឹងថាក្នុងរបបខ្មែរក្រហម ដែលពួកគេតែងតែអួតអាងថា ជារបបដែលគ្មានអំពើពុករលួយ ជារបបដែលស្ត្រី និងបុរសមានសិទ្ធិស្មើភាពគ្នា ជារបបដែលស្អប់ខ្ពើមអំពើខុសសីលធម៌ពាក់ព័ន្ធនិងផ្លូវភេទ តាមពិតជារបប ព្រៃផ្សៃដូចគ្នានឹងរបបផ្តាច់ការដូចតែគ្នាដែរ។

ទំនាក់ទំនងរវាងអំពើហិង្សានៅអតីតកាល និងបច្ចុប្បន្នកាលក៏ជារឿងមួយដែលគួរយកចិត្តទុកដាក់ដែរ ។ មនុស្សគ្រប់រូបមិនអាចផ្លាស់ប្តូរអតីតកាលបានទេ ចូរយើងធ្វើយ៉ាងណារស់នៅក្នុងបច្ចុប្បន្នឲ្យមានសេចក្តីសុខដើម្បីឲ្យអនាគតរបស់យើងមានសេចក្តីសុខដែរ ។ ការស្វែងរកការព្យាបាលគឺជាដំណោះស្រាយមួយដ៏ល្អដើម្បីដោះស្រាយរឿងរ៉ាវប៉ះទង្គិចពីអតីតកាល ។ ស្ត្រីមិនមែន ជាឧបករណ៍ សម្រាប់ឲ្យបុរសរំលោភបំពាននោះទេ គាត់មានសិទ្ធិស្មើៗគ្នាក្នុងនាមជាមនុស្ស ។ សូមបញ្ឈប់រំអំពើហិង្សា និងទារុណកម្មលើស្ត្រី!

សង្ឃឹមថា សៀវភៅនេះអាចឲ្យអ្នកអានដឹងពីហេតុការណ៍ពិតដែលកើតឡើងនាសម័យនោះ និងជាពិសេសទៀតដឹងពូការពិត ពីផលប៉ះពាល់នានាលើជីវិតរបស់ស្ត្រីដែលរងគ្រោះនៅក្នុងរបបខ្មែរក្រហម និងរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារបើទោះជា សង្ត្រាមបានចប់ក៏ដោយនោះ ។

សុក ស៊អៀន

នាយកប្រតិបត្តិ
ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

Foreword

The Khmer Rouge regime collapsed more than three decades ago but every time survivors from this regime talk about their sufferings they are still emotionally aroused and cannot bear nonstop-tears as it was a very horrifying they never believed they could survive. They were constantly worried about their lives and the killings. So far, Cambodian people have not considered much about violence against women.

Women were raped by Khmer Rouge before they were killed.This fact was a mystery or at least only few people knew this because the victims died. There are not many rape survivors and they do not want to be reminded or talk about it because they wonder what they would get if they talked about it, where they could find the perpetrators and who was responsible for it. Some women were forced to marry Khmer Rouge soldiers whom they did not love.They had to accept their destiny that someone else set for them. Many men were killed but women experienced different types of violence. They lived with sadness and missed their husbands and children who were taken to be killed by the Khmer Rouge; they witnessed their beloved children starving and being forced to work without proper food and rest. There were also Khmer Rouge female cadres who were raped by their commanders or their heads of unit who then accused them of committing mistakes.

What happened in the past should never happen again.Therefore, this book is very important to prove to the next generation what happened in that regime.The Khmer Rouge themselves claimed that their leadership was free of corruption, a regime under which men and women were treated equally, and where any act in relation to sexuality is considered a misconduct, but in fact it was a dictatorship.

The connection between the past violence and the present violence is important to consider as well. We cannot change the past but to live in the present happily for a happy and prosperous future we need to face the past. Seeking psychotherapy is a good solution to deal with past traumas.
Women are not objects that man can use. They are born with the same rights as every human being. Together we can end violence against women!

I hope this book contributes to the awareness on what happened during the Khmer Rouge era and especially to understand the impact of forced marriage on women's lives.

SOK Sam Oeun

Executive Director
Cambodian Defenders Project

សេចក្តីផ្តើម និងសារតារឿង

របបកម្ពុជាប្រជាធិបតេយ្យដែលគេនិយមហៅថាខ្មែរក្រហម បានគ្រប់គ្រងដឹកនាំប្រទេសកម្ពុជាពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ ស្ថិតក្រោមមនោគមវិជ្ជា និងការដឹកនាំនៃរបបនេះ ប្រជាជនស្លូតត្រង់ប្រមាណ ១.៧លាននាក់ បានស្លាប់ ។ ក្នុងរយៈពេលដ៏ត៨ឆ្នាំនៃការគ្រប់គ្រងដឹកនាំប្រទេស ប្រជាជនស្ទើរតែទាំងអស់ត្រូវបានពួកខ្មែរក្រហមចាត់ទុក ដូចជាសត្វ ។ សិទ្ធិ និងសេចក្តីថ្លៃថ្នូរត្រូវបានគេដកហូតទាំងស្រុងចេញពីមនុស្ស ដែលអ្វីៗទាំងអស់ស្ថិតតែនៅក្នុងកណ្តាប់ដៃខ្មែរក្រហម ឬ "អង្គការរបដិវត្តិ ឬ អង្គការ" ជាឈ្មោះដែលប្រជាជនបានឮជាទូទៅប្រចាំថ្ងៃ ។ ជារៀងរាល់ថ្ងៃ ប្រជាជនទាំងមូល បានទទួលរងការឈឺចាប់អំពីការបង្ខំឲ្យផ្លាស់ពីកន្លែងមួយទៅកន្លែងមួយ ការបង្ខំឲ្យបែកព្រាត់ព្រាស់ពីគ្រួសារ និងអ្នកដែលខ្លួនស្រឡាញ់ ការបង្ខំឲ្យធ្វើការហួសកម្លាំងដោយមិនបានផ្តល់អាហារឲ្យបានសមរម្យ គ្រោះអត់ឃ្លាន ការសម្លាប់ការស្លាប់ដោយ ជម្ងឺដោយមិនបានទទួលការថែទាំព្យាបាល ការទទួលរងទារុណកម្មនានា ។ល។ ក្នុងពិភពលោកនេះយើងបានចាត់ទុកថាការ រំលោភគឺជាអាវុធមួយក្នុងសង្គ្រាម ហើយការរំលោភនេះគឺពិតណាស់ វាពិតជាបានកើតឡើងក្នុងសម័យខ្មែរក្រហម ។ មានអំពើហិង្សាផ្លូវភេទជាច្រើនប្រភេទបានកើតឡើងដែលរួមមានការចាប់រំលោភ ការបំពារបំពានឬ ធ្វើរបៀនកាយ និង ផ្លូវភេទ (បង្ខំឲ្យដោះសម្លៀកបំពាក់ដើម្បីបង្ហាញកាយរាក្រាតជាការកម្សាន្ត កាត់រាវះយះភេទ) ការបង្ខំចិត្តរួមភេទដោយ សារតែជាថ្នូរនឹងអ្វីមួយ (អាហារ តំណែង/តួនាទី មិនធ្វើការការពារនិងគ្នា មិនរងការធ្វើបាប ។ល។) ការបង្ខាំង ឬបង្ខំឲ្យធ្វើការ នៅកន្លែងណាមួយក្នុងបំណងកេងប្រវ័ញ្ចផ្លូវភេទ និងការបង្ខំឲ្យរៀបការ ។ មនុស្សជំនាន់ក្រោយដែលមិនបានឆ្លងកាត់របបនោះ បានសួរហាក់ដូចជាមិនចង់ជឿថា តើរឿងនេះបានកើតឡើងមែនឬអត់ ពីព្រោះពួកគេឮថាបានដឹងតគ្នាថា ការខុសសីលធម៌រវាង បុរស និងស្ត្រីគឺជារឿង ដែលខ្មែរក្រហមចាត់ទុកថាគឺងតែងបំផុត បើនរណាម្នាក់ហ៊ានខុសសីលធម៌អ្នកនោះ នឹងត្រូវបានយកទៅសម្លាប់ចោល ។ ការពិតនោះគ្រាន់តែជាគោលការណ៍ ឬគោលនយោបាយតែលើក្រដាសប៉ុណ្ណោះ ។ សួរថាតើនរណាខ្លះជា អ្នកបានរំលោភស្ត្រី? តើប្រជាជន ឬកសិករធម្មតាម្នាក់បានរំលោភឬ? ...ការពិតគឺសុទ្ធតែខ្មែរក្រហមទាំងអស់ជាអ្នកធ្វើ ។

កម្មវិធីអំពើហិង្សាផ្លូវភេទក្រោមរបបខ្មែរក្រហមជាកម្មវិធីមួយរបស់អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ។ ក្នុងកម្មវិធីនេះមានអ្នកចិត្តសាស្ត្រម្នាក់បានកំពុងធ្វើការជាមួយអ្នកនៅរស់ពីរបបខ្មែរក្រហមតាមរយៈការបង្កើតជាក្រុមជួយខ្លួនឯង ដើម្បីសម្រប សម្រួលដំណើរការព្យាបាលរបស់ពួកគាត់ ។ នៅក្នុងក្រុមមួយនៃក្រុមជាច្រើនទៀត អ្នកជំនាញរបស់យើងបានធ្វើការជាមួយ ក្រុមមួយដែលមានសមាជិកជាស្ត្រីចំនួន៨រូបដែលពួកគាត់សុទ្ធតែត្រូវបានរងគ្រោះពីការបង្ខំឲ្យរៀបការ ពីសំណាក់ខ្មែរក្រហម ។ គម្រោងនេះមានរយៈពេលមួយឆ្នាំពេញដោយបានចាប់ផ្តើមក្នុងខែមិថុនា ឆ្នាំ២០១១ ដល់ខែមិថុនាឆ្នាំ ២០១២ ។ សមាជិក ក្រុម៨នាក់ជាស្ត្រីមេម៉ាយប្តីស្លាប់ ហើយ៨នាក់ទៀតរស់នៅជាមួយប្តី (ពីរនាក់រស់នៅជាមួយប្តីដែលត្រូវបានខ្មែរក្រហមបង្ខំឲ្យ រៀបការ និងពីរនាក់ទៀតបានរៀបការម្តងទៀតក្នុងអំឡុងឆ្នាំ ១៩៨០) ។ ស្ត្រីពីរនាក់ក្នុងចំណោមសមាជិកក្រុម កំពុងរស់នៅក្នុង អំពើហិង្សាគ្រួសារ ដែលទំនងជាអាចបណ្តាលមកពីភាពក្រីក្រ និងការប៉ះទង្គិចផ្លូវចិត្តដែលទាំងប្តី ទាំងប្រពន្ធបានទទួលរងពី សម័យខ្មែរក្រហម ។ ប្តីបញ្ចេញអារម្មណ៍ក្រោធ ស្អប់ ប្រច័ណ្ឌរបស់ខ្លួនតាមរយៈការស្តីបន្ទោសនិងការវាយដំប្រពន្ធរបស់គាត់។

គាត់មិនបានរៀនវិធីល្អៗក្នុងការគ្រប់គ្រងកំហឹងរបស់ខ្លួននោះទេ ហើយលើសពីនោះទៅទៀតគាត់ថែមទាំង បដិសេធន៍ការជួយ ពីអ្នកជំនាញរបស់យើងទៀតផង ។ វាបានក្លាយជារឿងធម្មតាសម្រាប់បុរសក្នុងការបញ្ចេញហិង្សាទាំងអស់នោះ

ដោយមិនបានដឹងថាកំពុងធ្វើខុសនោះទេ ។ បុរសខ្លះបានគិតថាខ្លួនមានសិទ្ធិក្នុងការវាយដំប្រពន្ធកូន ប៉ុន្តែនោះជាការយល់ខុសទាំងស្រុង ។ នេះប្រហែលជារាងជាថ្នែកមួយដោយសារតែទំហំនៃការប៉ះទង្គិចផ្លូវចិត្តដែលពួកគាត់បានឆ្លងកាត់ពីកុមារភាពក៏ជួចជាពីសម័យខ្មែរក្រហម ។

នៅក្នុងស្ថានភាពនេះប្រពន្ធដែលបានទទួលរងការប៉ះទង្គិចផ្លូវចិត្តច្រើនជ្នួនៗ ក្នុងអំឡុងពេលសង្ក្រាមដែលក្នុងនោះ រួមទាំងការបង្ខំឲ្យរៀបការ ការចាប់រំលោភ ត្រោះស្រេកឃ្លាន ការប៉ប៉ៃកដោយបង្ខំ ការបង្ខំឲ្យធ្វើការលើសកម្លាំង ហើយមកដល់បច្ចុប្បន្ធនេះ គាត់នៅតែបន្ធរងការឈឺចាប់ពីអំពើហិង្សាពីប្តីរបស់ពួកគាត់ ដែលប្តីរបស់គាត់តាមពិតទៅគួរតែជាមនុស្សម្នាក់ដែលគាំទ្រគាត់ឲ្យ សះជាពីរបួសផ្លូវចិត្តពីអតីតកាលនោះ ។

ធ្វើការជាមួយពួកគាត់ អ្នកចិត្តសាស្ត្របានដឹងថាពួកគាត់ពិតជាមានពេលតិចតួចណាស់ ដែលសប្បាយក្នុងជីវិតរបស់គាត់ទាំងមូល ។ លើសពីនេះទៅទៀតដោយសារតែការប៉ះទង្គិចផ្លូវចិត្តផ្ទាល់ ពួកគាត់មិនអាចមានលទ្ធភាពក្លាហានត្រប់ត្រាន់ក្នុងការ ដើរចេញពីសម្ព័ន្ធភាពដ៏ឈឺចាប់នោះទេ ។ អ្នកចិត្តសាស្ត្របារម្ភពីភាពប្រថុយប្រថានក្នុងការចម្លង ការប៉ះទង្គិចផ្លូវចិត្តរបស់ពួកគាត់ (ប្តីប្រពន្ធ) ទៅកាន់កូនៗនិងចៅៗរបស់គាត់ទៀត ។ តាមការសិក្សាស្រាវជ្រាវបានបង្ហាញថារោគសញ្ញាមួយចំនួនរបស់ការប៉ះទង្គិចផ្លូវចិត្តពីឱពុកម្តាយពិតជាអាចបន្ធប៉ះពាល់ ដល់កូនចៅជ៉នាន់ក្រោយៗ ។

សម្រាប់ជនរងត្រោះបីនាក់ទៀត ដែលប្តីរបស់គាត់បានស្លាប់ហើយនោះ ពួកគាត់បាននិយាយថាពួកគាត់មានជីវិតប្រសើរជាងមុន បន្ទាប់ពីប្តីរបស់គាត់បានស្លាប់ ។ បើទោះបីជាគាត់ត្រូវធ្វើការងារច្រើនធ្ងន់ធ្ងរយ៉ាងណាដើម្បីចិញ្ចឹមកូនក៏ប្រសើរជាងធ្វើការធ្ងន់ហើយត្រូវតែវាយធ្វើបាបដែរ ។ ម្នាក់ក្នុងចំណោមពួកគាត់បាននិយាយថា "ខ្ញុំយល់ថាខ្ញុំសប្បាយចិត្តជាងមុនច្រើនតាំងពីប្តីខ្ញុំបានស្លាប់មក ។ គាត់ស្រវឹងស្រាស្ទើតែរៀងរាល់ថ្ងៃ គាត់វាយធ្វើបាបខ្ញុំគាត់ប៉ន្លាញលុយ ដែលខ្ញុំខំសន្សំ..." ។

ប្រហែលជាពីរបីឆ្នាំមុនសមាជិកម្នាក់ក្នុងក្រុមត្រូវបានអ្នកនៅក្នុងភូមិស្នូរនាំចង់ស្តីដណ្តឹងរៀបការ ប៉ុន្តែគាត់បានបដិសេធន៍ ហើយបាននិយាយនៅក្នុងក្រុមថា "...ខ្ញុំសប្បាយចិត្តហើយឥឡូវនេះ ។ ទំរាំតែបានរួចខ្លួនពីតុកយូរណាស់ម៉េចបានខ្ញុំត្រូវទៅ ចូលតុកវិញម្តងទៀត" ។

អ្នកចិត្តសាស្ត្រយល់ថា ទម្រង់នៃអំពើហិង្សាជាច្រើនកើតឡើង ដោយសារតែមានអ្វីបានកើតឡើងនៅក្នុងអតីតកាលដែលនៅតែមិនបានព្យាបាលឬដោះស្រាយ ហើយធ្វើឱ្យអ្នកទាំងនោះមានអារម្មណ៍ និងបញ្ចេញអាកប្បកិរិយាខុសប្លែកពីខ្លួនឯងពីមុនពេលជួបបញ្ហា ។ បុគ្គលម្នាក់នោះមិនអាក្រក់ទេ អាកប្បកិរិយាអាក្រក់ដែលគាត់ធ្វើទាំងអស់នោះសុទ្ធតែជាលទ្ធផលមកពីការប៉ះ ទង្គិចផ្លូវចិត្តដែលគាត់ឆ្លាប់បានជួបហើយមិនបានព្យាបាលដោះស្រាយ ។

ក្រុមជួយខ្លួនឯងដែលមានសមាជិកទាំង ៨នាក់នេះត្រូវបានរៀបចំបែងចែកជា ១២ជំនួបក្នុងមួយឆ្នាំ ដែលមាន ៧ជំនួបធ្វើនៅភ្នំពេញ និង៣ជំនួបទៀតធ្វើនៅខេត្តពោធិសាត់ (ក្នុងឆ្នះរបស់ពួកគាត់ម្នាក់ម្តង) ។ ជំនួបទាំងបីដងដែលធ្វើនៅខេត្តពោធិសាត់នោះ ក្នុងបំណងបង្រៀន និងមើលថាតើពួកគាត់អាចនឹងរៀបចំជំនួបបែបនេះនៅភូមិស្រុករបស់គាត់បានដែរឬទេ នៅពេលដែលគម្រោងនេះត្រូវបញ្ចប់ ។ នៅពេលជំនួបក្រុមម្តងៗជារៀងរាល់ខែយើងមានសកម្មភាពជាច្រើនជួចជា សកម្មភាពដែលទាក់ទងនឹងការព្យាបាលផ្លូវចិត្ត តាមបែបសម្តែង និងសិល្បៈបច្ចេកទេសព្យាបាលមួយចំនួនដោយការប្រឈមជាមួយការប៉ះទង្គិចផ្លូវចិត្ត ការកសាងនិងពង្រឹងការជឿជាក់ ក្នុងលំហាត់ និងសកម្មភាពជាច្រើនទៀតដែលបង្ហប់ន័យអប់រំរៀនសូត្រ និង លំហាត់សម្រាកកាយចិត្តមួយចំនួនទៀត ។

សៀវភៅនេះសរសេរឡើងដោយមានការសម្ភាសន៍យ៉ាងល្អិតល្អន់ស៊ីជម្រៅ ដោយអ្នកចិត្តសាស្ត្រដើម្បីប្រមូលព័ត៌មានពីស្ត្រីរបស់ យើងដែលចូលរួមក្នុងសៀវភៅនេះ ។ រាល់ការសម្ភាសន៍ទាំងអស់ត្រូវបានធ្វើឡើងក្នុងកន្លែងស្ងាត់ជាច់ពីគេ តាមតែពួកគាត់ចង់បាន ឬសម្ភាសន៍នៅក្នុងបន្ទប់ស្ងាត់នៅ ក្នុងផ្ទះមួយរបស់សមាជិកក្រុមម្នាក់ ។ កិច្ចសម្ភាសន៍និមួយៗចំណាយពេលប្រហែល មួយម៉ោងកន្លះទៅពីរម៉ោងអាស្រ័យ លើសាច់រឿងដែលពួកគាត់បានចែករំលែក ។ ម៉ាស៊ីនថតសម្លេងក៏ត្រូវបានប្រើអំឡុង ពេលសម្ភាសន៍ដែរ ដើម្បីឲ្យប្រាកដថាព័ត៌មានដែលយកមកសរសេរថាព័ត៌មានត្រឹមត្រូវពិតប្រាកដ ។ នៅពេលមុនធ្វើការសម្ភាសន៍ អ្នកសម្ភាសន៍ បានជំរុញពួកគាត់ឡើងវិញពីគោលបំណងនៃការចងក្រងសៀវភៅនេះ ពន្យល់ពីប្រយោជន៍ និងភាពប្រថុយប្រថានដែលអាចកើតមាន និងជាពិសេសបានបញ្ជាក់យ៉ាងច្បាស់ពីសារសំខាន់នៃការចូលរួមរបស់ ពួកគាត់ ។ យើងក៏បានទទួលការយល់ព្រមពីពួកគាត់ ។ ការគោរពសេចក្តីថ្លៃថ្នូរ និងភាពឯកជនត្រូវបាន ប្រកាន់ខ្ជាប់នៅក្នុងដំណើរការសម្ភាសន៍ទាំងមូល ។

"ខ្ញុំយល់ថាខ្ញុំសប្បាយ ចិត្តជាងមុនច្រើនតាំងពីប្តីខ្ញុំបានស្លាប់មក ។
គាត់ស្រវឹងស្រា
ស្ទើតែរៀងរាល់ថ្ងៃគាត់វាយធ្វើបាបខ្ញុំគាត់បំផ្លាញលុយ ដែល ខ្ញុំខំសន្សំ..." ។

"... I found myself much happier since my husband died.
He was drunk
nearly every day, he beat me, he spent all the money I saved..."

Introduction and Background of the book

Democratic Kampuchea, known as the time of the Khmer Rouge (KR) regime, ruled Cambodia from 17 April 1975 to 6 January 1979. Under its ideology and leadership 1.7 million people died. In the nearly four years in which the KR ruled the country the entire populations were treated inhumanely. Human rights and dignity were taken away from people by the KR, who commonly referred to their regime as the "Angka revolution" or "Angkar". The whole population suffered from forced evacuation from one place to another, forced separations from love ones, forced labor without proper food, starvation, killing, slaughter, disease, and torture on a daily basis. On a global level rape is considered to be a weapon of war; and this crime occurred during the KR era as well. There were many types of sexual violence that happened during this time, including rape, sexual mutilation, sex trading, sexual exploitation and forced marriage. Younger generations heard stories from the older generation that during the KR era, engaging in sexual relations was considered to be gross misconduct byAngka, punishable by death. They have therefore questioned whether these forms of sexual violence actually occurred. In reality,these acts were rarely committed by normal people. It was the KR themselves who perpetrated these sexual crimes.

As part of the Cambodian Defenders Project's (CDP) Gender Based Violence Project (GBV) a psychologist has been working with survivors of the KR through Self Help Groups to facilitate the healing process. In one of these groups, the psychologist works with a group of eight women who suffered from forced marriage under the KR regime. This project started in June 2011 and ran until June 2012. Four of the group members are widows and four are still married to their husband (two from the forced marriages, and another two who remarried during the 1980s). Two of the group members are living in chronically violent relationships which could be caused by poverty and the trauma that both of the women's husbands suffered during the KR regime. The husbands release their suppressed feelings of anger, hatred, jealousy etc. by blaming and beating their wives. They don't learn about healthy ways to manage or release anger, and they refuse the offer of help from our experts. It is common for domestically violent men not to realize that their behavior is wrong. This is partly because of how much they suffer from trauma.

The wives in this situation have also greatly suffered from the traumas that they experienced during the war including those arising from forced marriage, rape, starvation, separation, forced labor etc. These two women continue to suffer from violence at the hands of their husbands – the very person who should be the one to support them to come to terms with their past traumas.

Working with them, the Psychologist has found that they very rarely experience happiness in life. Furthermore because of their own trauma, they do not dare walk away from their painful relationships. The Psychologist is concerned about the risk of that they will pass their traumas onto their children and grandchildren. Research has proven that trauma can be passed to future generations.

The other four victims whose husbands have died, state that their life is better since their husbands passed away. Although they are required to work harder to raise their children on their own, their life is happier than working hard and getting beaten. One of them said "... I found myself much happier since my husband died. He was drunk nearly every day, he beat me, he spent all the money I saved..."A few years ago one group member was proposed to by her neighbor, but she refused and told the group during the meeting "... I was happy to get out of the prison, why should I walk into it again?"

The Psychologist found that many types of violence occur because there is something in the violent person's past that remains unsolved and makes them behave differently from how they were before this event took place. The person is not bad - these behaviors are a result of trauma that they have suffered. Complex traumas definitely change people's personalities Therefore, psychotherapy is significant and necessary to change behavior is a positive way.

The self-help group for these eight women was a one year project which met once a month. The group had twelve meetings, seven of which occurred in Phnom Penh and three in Pursat (in their house). The three meetings in the province aimed to encourage group members to commit to organizing more meetings at their own places when the project finished. There were many group activities involved in the CDP program, such as art and play therapy, some trauma confrontation technique therapy, team building activities aimed at building trust between group members, and other learning-related exercises and relaxing exercises.

In this book, individual in-depth interviews by psychologists were employed to collect information from our participants. All the interviews were conducted in a private and quiet place at the participants' preference or in a private room in one of the participant's house. Each interview lasted about one and a half to two hours according to the story shared by the participants. A voice recorder was used during the interview to make sure the information is accurate when using it for writing. At the beginning of each interview, the interviewer informed the participant of the purpose of the book, explained the potential benefits and risks and emphasized the importance of their participation. An informed consent was obtained. Respect, dignity and privacy were maintained throughout the interview process.

សេចក្តីថ្លែងអំណរគុណ

សៀវភៅមួយនេះនឹងមិនអាចចោះពុម្ពចេញមកបានទេប្រសិនបើមិនមានការជួយគាំទ្រពីមិត្តរួមការងារទាំងអស់ដែលធ្វើការនៅក្នុងគម្រោងអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហមនៃអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក ដួង សាវន ជាអ្នកសម្របសម្រួលគម្រោង និងកញ្ញា យ៉ី បេនី ជាទីប្រឹក្សាជាន់ខ្ពស់របស់គម្រោងសម្រាប់ ការជួយគាំទ្រ និងផ្តល់គំនិតដ៏មានតម្លៃនានាក្នុងដំណើរការទាំងមូលនៃការចងក្រងសៀវភៅនេះឡើង ។ ខ្ញុំក៏សូមអរគុណ ចំពោះអ្នកស្រី លាង ចរិយា ជាជំនួយការគម្រោងសម្រាប់ការជួយគាំទ្ររបស់គាត់ទាំងការជួយរៀបចំជំនួបប្រជុំ និង ដំណើរការ ផ្សេងៗពាក់ព័ន្ធនឹងការចងក្រងសៀវភៅនេះ ។ សូមអរគុណកញ្ញា ស្រ៊ា រត្នា ក្នុងការជួយនាងខ្ញុំក្នុងដំណើរការសម្ភាសន៍ ដើម្បីសរសេរសៀវភៅនេះ ។ នាងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះលោក សឹង សុធារ័ត្ន ចំពោះការជួយប្រែសម្រួលអត្ថបទ ជាភាសាខ្មែរ និង កញ្ញា ខេធ រ៉ូឌីតសុន សម្រាប់សណ្តានចិត្តដ៏ល្អរបស់នាង ក្នុងការជួយប្រែសម្រួល អត្ថបទជាភាសា អង់គ្លេស ។ សូមអរគុណចំពោះម្ចាស់ជំនួយ មេឌីកា មុងឌីយ៉ាល់ ដែលបានឧបត្ថម្ភថវិការសម្រាប់បង្កើតក្រុមជួយខ្លួនឯង និងថវិការសម្រាប់ ការចោះពុម្ពសៀវភៅនេះ ។

ជាចុងក្រោយ នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងក្រៃលែងចំពោះស្ត្រីដ៏រឹងមាំទាំងប្រាំបីរូប ក្នុងក្រុមជួយខ្លួនឯងមួយនេះ សម្រាប់ សេចក្តីក្លាហាន និង ការជឿជាក់លើដំណើរការក្នុងការជួយឲ្យពួកគាត់អាចទទួលយករឿងរ៉ាវអតីតកាលដ៏លើចាប់របស់ខ្លួន គាត់ស្គាល់បានដើម្បីឈានទៅរកការសះជា ។ នាងខ្ញុំពិតជាសូមកោតសរសើរយ៉ាងខ្លាំងចំពោះឆន្ទៈ និងអត្តចរិតដ៏ក្លាហាន របស់ពួកគាត់ក្នុងការហ៊ានប្រឈមជាមួយនឹងការប៉ះទង្គិចផ្លូវចិត្តដែលខ្លួនមាន ហើយទង្វើបែបនេះគួរតែក្លាយជាគំរូ សម្រាប់ជន រងគ្រោះដ៏ទៃជាច្រើនទៀត ។

Acknowledgments

This book would not be possible without the support from my colleagues at Gender Based Violence during the Khmer Rouge Regime at Cambodian Defender Project (CDP). Special thanks to Mr. DOUNG Savorn, project coordinator and Ms. Beini YE, senior advisor to the project for their support and comments in the process of making this book. Thank you to Ms. LEANG Charkya, the project assistant, for her support throughout the process and Ms. SREA Ratha for her help interviewing some clients with me. I would also like to say thank you to Mr. SEOUNG Sothearwat for editing the Khmer text and Ms. Katie ROBERTSON for her kind work editing the English text. Thank you to the donor Medica Mondiale who financed the self-help group and the printing of this book.

Finally, I would like to express my gratitude to the eight strong women of this self-help group for their courage and trust in the process supporting them to come to terms with their past. Their willingness and brave attitude to confront their traumas is highly appreciated and should be a good role model for many other survivors.

ប៉ែន សុខចាន់

អ្នកស្រី ប៉ែន សុខចាន់ អាយុ ៥១ឆ្នាំ រស់នៅភូមិ បឹងឈូក ឃុំ ខ្នារទទឹង ស្រុកបាកាន ខេត្តពោធិសាត់ ។ អ្នកស្រីជាកសិករ និងជាស្ត្រីមេម៉ាយ មានកូន ៦នាក់ ស្រី ៥នាក់ និង ប្រុស ១នាក់ជាកូនពៅដែលកំពុងរស់នៅជាមួយគាត់ ។

កាលពីមុនសម័យខ្មែរក្រហម អ្នកស្រីបានរស់នៅក្នុងភូមិកំពង់ក្តី ឃុំអូតាប៉ោង ស្រុកបាកានខេត្តពោធិសាត់ ។ គាត់ជាកូនទី២ ក្នុងគ្រួសារ មានម្តាយជាស្ត្រីមេផ្ទះ និងឪពុកធ្វើជាទាហាន ។ គាត់មិនបានរៀនសូត្រទេ ព្រោះគាត់ និងក្រុមគ្រួសារតែងតែផ្លាស់ទីតាមឪពុកនៅ ពេលគាត់ចេញទៅបំពេញបេសកកម្ម ឬធ្វើសង្គ្រាមម្តងៗ ។ ក្នុងសម័យសង្គ្រាម ខ្មែរក្រហម អ្នកស្រី និងគ្រួសារត្រូវបានគេជម្លៀស ពីកំពង់ក្តីមកបឹងឈូកនេះ ។

អ្នកស្រីត្រូវបានខ្មែរក្រហមចាត់ឲ្យចូលក្នុងក្រុមកងចល័តកុមារ ធ្វើការជាអ្នកជីកដី និងលាយជីលាមកអាចម៍ ។ បន្ទាប់មកគាត់បានធ្វើការជាអ្នកលាយជីលាមកអាចម៍នោះជាមួយនឹងនារីដទៃៗទៀត ដោយប្រើដៃរជើងផ្ទាល់តែម្តង ។ អ្នកស្រី បានរៀបរាប់ថា "វ័យ១៦ឆ្នាំជាវ័យដែលជូរចត់ ឈឺចាប់បំផុតសម្រាប់ខ្ញុំ ។ ខ្មែរក្រហមបានបង្ខំឲ្យខ្ញុំធ្វើការកាន់តែខ្លាំងឡើង ខ្ញុំព្រាត់ប្រាស់ឪពុកម្តាយ បងប្អូន ត្រូវគេបង្ខំឲ្យរៀបការទាំងនៅក្មេងមិនទាន់ទាំងគ្រប់ការផង។ ខ្ញុំឃើញផ្ទាល់ភ្នែកពេលដែលខ្មែរក្រហមចាប់អូសយកឪពុកខ្ញុំទៅសម្លាប់ ។ ទោះបីខ្ញុំមិនបានឃើញខ្មែរក្រហមសម្លាប់ឪពុកខ្ញុំក៏ដោយ តែខ្ញុំបានដឹងថាគាត់ត្រូវបានគេសម្លាប់ ហើយក្រោយពេលដែលគេបានចាប់យកទៅនោះ..." ។ អ្នកស្រីបានបន្តមទៀតថា រហូតមកដល់ពេលនេះ គ្រប់ការស្លាប់ទាំងអស់ ទោះបីជាសាច់ញាតិក្រុមគ្រួសារមិត្តភក្តិ ឬអ្នកដទៃក៏ដោយក៏ធ្វើឲ្យប៉ះពាល់ដល់គាត់ខ្លាំងណាស់ដែរ ។ អ្នកស្រីបានរៀបការនៅចុងឆ្នាំ ១៩៧៨ ចន្លោះប្រហែលជាម៉ោង ៩:៣០ ទៅម៉ោង ១០យប់ នៅឃុំដើមរកា ខណៈពេលដែលគាត់ទើបតែត្រឡប់មកពីស្លុង ។ បន្ទាប់ពីមកពីស្រែ អ្នកស្រីត្រូវបានគេប្រាប់ថានឹងត្រូវទៅរៀបគ្រួសារ ដោយអ្នកស្រីមិនដឹងថាបុរសម្នាក់នោះជានរណា ឈ្មោះអ្វីនោះទេ ។ នៅថ្ងៃដែលគាត់រៀបគ្រួសារនោះ មាន១៥គូត្រូវបានខ្មែរក្រហមបង្ខំដែរ ហើយគាត់មានវ័យក្មេងជាងគេ ដែលពេលនោះ អ្នកស្រីនៅមិនទាន់ពេញវ័យគ្រប់ការ នៅឡើយទេ ។ "...ខ្ញុំភ័យស្ទើរស្លាប់ ហើយយំយ៉ាងខ្លាំង" ។ យប់ថ្ងៃរៀបការនោះ មានភ្លៀងយ៉ាងខ្លាំង ទើបធ្វើឲ្យគាត់អាចរួចខ្លួនពីការបង្ខំឲ្យរួមដំណេកបានមួយយប់បើទោះបីជាមានឈ្លបតាមជាន់គាត់ក៏ដោយ ។

ត់នូរស្នឹងជីវិត ប៉ែន សុខចាន់

អ្នកស្រីត្រូវបានប្តីបង្ខំរលោភបានៅយប់ទី ២ ដោយគេចាប់សង្កត់ដៃទាំងពីរទៅក្រោយ ហើយវាយទះកំផ្លៀងរួចសំភាគសំលៀកបំពាក់ តែម្តង ។ នៅយប់ទី៣ គាត់បានសម្រេចចិត្តលួចរត់ចេញពីកន្លែងនោះទៅរកម្តាយតែម្តង ។ រឿងការបង្ខំឲ្យរៀបការនេះ អ្នកស្រីបានលាក់វាអស់ជាច្រើនឆ្នាំមកហើយ គាត់ឆ្លាប់បានគិតថានឹងលាក់រឿងអាស្រូវនេះកប់ទៅក្នុងផ្នូរជាមួយគាត់នៅពេលស្លាប់ ។ ប៉ុន្តែចន្លុះភាគច្រើននៅក្នុងភូមិ របស់គាត់ជាពិសេសកូនៗរបស់គាត់បានដឹងរឿងរ៉ាវទាំងអស់នេះ នៅពេលដែលគាត់បានសម្រេចចិត្ត ថតខ្សែភាពយន្តមួយឈ្មោះថា "អាពាហ៍ពិពាហ៍ក្រហម" ដែលបានលាតត្រដាងការពិតពីក្រវ៉ាត់ដ៏ជូរចត់ទាំងអស់នោះ ។ កូនៗរបស់គាត់ មានការភ្ញាក់ផ្អើលនៅពេលដែល ដឹងរឿងនោះ ប៉ុន្តែពួកគេក៏ជួយគាំទ្រលើកទឹកចិត្តម្តាយច្រើនដែរ ។ ប្តីដែលធ្លាប់បានគេបង្ខំឲ្យរៀបការ នោះ បានបែកគ្នាតាំងពីពេលដែលអ្នកស្រីរត់ចេញនោះមកម្ល៉ះ ហើយគាត់បានឮថាគាត់ធ្លាប់បានខ្មែរក្រហមសម្លាប់ហើយ ។ អ្នកស្រីបានរៀបការម្តងទៀតនៅឆ្នាំ ១៩៨០ ដោយមានការ ដឹងឮ និងយល់ព្រមពីចាស់ទុំ ខុសពីការរៀបការលើកមុន ។ ប្តីបស់គាត់ជាទាហានម្នាក់ ដែលគាត់ក៏ឆ្លាប់បានរៀបការពីសម័យខ្មែរក្រហមហើយក៏បែកចាក់គ្នាដែរ ។ ពេលវេលាដែលអ្នកស្រី និងប្តី ស្រឡាញ់គ្នា យល់ចិត្តគ្នា មិនឈ្លោះប្រកែកគ្នា មានមិនយូរប៉ុន្មានឡើយ ។ បន្ទាប់ពីមានកូនទី ៣មក ទំនាក់ទំនងគ្រួសារអង្គោះរង្គើរ ប្តីបស់គាត់មានទំនាក់ទំនងខាងក្រៅជាច្រើនលើកច្រើនសារ មានការប្រើអំពើហិង្សាទាំងផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទមកលើគាត់ ។ អ្នកស្រីត្រូវរស់នៅជាមួយម្តាយ ទទួលបន្ទុកមើលថែទាំកូនទាំងអស់តែម្នាក់ឯង ។ គាត់ប្រកបរបរធ្វើស្រែចំការ ដើរកាទិញស្វាយ ត្រួច ពីអ្នកភូមិទៅលក់នៅផ្សារដើម្បីបានប្រាក់ចំណេញបន្តិចបន្តួចមកទិញម្ហូបអាហារ និងឲ្យកូនរៀន ។ ដោយសារជីវភាពលំបាកកូនៗ របស់គាត់មិនបានរៀនបានខ្ពង់ខ្ពស់ទេ ប៉ុន្តែគាត់កំពុងតែព្យាយាមជួយប្រាម ត្រែងឲ្យកូនប្រុសពៅ របស់គាត់បានរៀនសូត្រឲ្យបានខ្ពង់ខ្ពស់នឹងគេ ។ ដោយសារប្តីរបស់គាត់ជាទាហាន ពេលត្រែងរំពើហិង្សាម្តងៗ ជាញឹកញាប់គាត់យក កាំភ្លើងមកភ្ជង់ ឬ ចាក់ឡើងលើ ឬចាក់ជីរដើម្បីជាការគម្រាម ។ ប្តីរបស់គាត់ បានស្លាប់កាលពីឆ្នាំ ១៩៩៣ ។ អ្នកស្រីបាននិយាយថា "...បើប្តីខ្ញុំរស់ក៏ខ្ញុំមិនអាចរស់បានដល់ឥឡូវនេះដែរ" ។ អ្នកស្រីមិនបានរៀបការទៀតទេតាំងពីប្តីរបស់ អ្នកស្រីស្លាប់មក។ អ្នកស្រីបាននិយាយថា "ទំភ័ក់តែបានចេញពីគុកយូរណាស់ ខ្ញុំមិនចង់ចូលគុកវិញទៀតទេ" ។ អ្នកស្រីយល់ថា ជីវិតប្តីប្រពន្ធរបស់គាត់ និងសង្គ្រាម ដែលបានឆ្លងកាត់មានភាពជូរចត់ ឈឺចាប់ ដូចគ្នា ។ រហូតមកដល់ សព្វថ្ងៃនេះ អ្នកស្រីតែងតែគេចវេស មិនចង់ឃើញ មិនចង់ឮអំពើហិង្សា ក្នុង គ្រួសារទេ ។

នៅខែមិថុនា ឆ្នាំ២០១១ អ្នកស្រីនិងសមាជិកក្រុមចំនួន ៨នាក់ទៀត ជាស្ត្រីពីលាមានបទពិសោធន៍ ស្រដៀងគ្នាបានចូលរួមក្របមួយ ឈ្មោះថាក្រុមជួយ ខ្លួនឯង ។ ក្រុមនេះមានរយៈពេល ១ឆ្នាំពេញ ហើយតែងតែជួបគ្នាជារៀងរាល់ខែ ។ គាត់សប្បាយ និងពេញចិត្តនឹងក្រុមនេះណាស់ ព្រោះគាត់យើញថាម្នាក់ៗល្អជាមួយគ្នា យល់ចិត្តគ្នា ។ ក្រុមទាំងមូល និងសកម្មភាពនានា នៅក្នុងក្រុមពិតជាបាន រួមចំណែកច្រើនក្នុងការជួយព្យាបាលរបួសផ្លូវចិត្តរបស់គាត់ ដោយសកម្មភាពទាំងអស់នោះធ្វើឲ្យគាត់អាចពិចារណា បានច្រើន និងស៊ីជម្រៅទៅលើបញ្ហារបស់គាត់ជាពិសេសគាត់មានកម្លាំងចិត្ត ច្រើន ដើម្បីប្រឈមជាមួយនឹងបញ្ហារបស់គាត់ ។ សកម្មភាពដែល អ្នកស្រីចូលចិត្តខ្លាំងគឺ ការគូរូប ការពិគាក្សាពិបញ្ហាដើម្បីឲ្យក្រុមទាំងមូលជួយ រកដំណោះស្រាយនិងគាំទ្រ ការលេងសើចសប្បាយ ជាមួយក្រុម លំហាត់ដើមឈើ លំហាត់ជង្ហើមដែលជួយសម្រួលការសំរាន្ត និងជួយសម្រួល កំហឹងដែលគាត់មានម្តងម្កាល ជាពិសេស ទៀតគាត់ចូលចិត្តសកម្មភាពពិធីបិទដោយប្រើដីខ្សាច់ ។ អ្នកស្រីគិតថានឹងនៅតែបន្តគាំទ្រ សមាជិកក្រុម របស់គាត់ទៀត ដោយនៅតែព្យាយាមរកឱកាសជួបគ្នា ជាពិសេសមានពិធីបុណ្យកម្តងៗ ។ អ្នកស្រីគិតថាការចងក្រងជាក្រុមរវាងអ្នកដែលធ្លាប់ មានបទ ពិសោធន៍ឈឺចាប់ដូចគ្នាបែបនេះមានប្រយោជន៍ណាស់ព្រោះពួកគាត់អាចចែករំលែកអារម្មណ៍ ជួយគាំទ្រគ្នា ធ្វើឲ្យគាត់មានអារម្មណ៍ ធូរស្រាល ចង់មានសុខភាពល្អជាងមុន ហើយធ្វើឲ្យគាត់ចង់ស្អាតជាងមុនទៀត ។ អ្នកស្រីសង្កេតឃើញថាគាត់មានភាពផ្លាស់ប្តូរ បន្ទាប់ពីបានចូលរួមក្រុមជួយខ្លួនឯងនេះ ដោយគាត់ដឹងថាខ្លួនគាត់អាចគ្រប់គ្រងអារម្មណ៍បានល្អជាងមុន មិនសូវឆេវឆាវ អត់ធ្មត់លែងតឹយខ្លាចដូចមុន មិនប្រើហិង្សា ជាក់កូន មិនចូលចិត្តលាក់អារម្មណ៍ហើយគិតច្រើនតែម្នាក់ឯង សំរាន្តលក់ជាងមុន និងឡើង តឹឡជាងមុន ។ អ្នកស្រីចង់និយាយទៅកាន់ជនរងគ្រោះពីការបង្ខំឲ្យរៀបការ និងការរំលោភបំពានផ្លូវភេទឲ្យរួងទៀត ឲ្យគាត់មានការគិត វិភ្ជមានពីខ្លួនឯងនិងពីជីវិតកុំព្យាយាមសម្ងំលាក់ខ្លួនជាមួយនឹងបញ្ហាដែលមាន ត្រូវក្រោកឈរឡើងជួយខ្លួនឯង និងស្វែងរកជំនួយ ។ ទោះជាយ៉ាងណាយល់សប្តិ អាក្រក់នៅតែបន្តប៉ះពាល់ខ្លះៗដល់ជីវិតប្រចាំថ្ងៃរបស់គាត់ ប៉ុន្តែគាត់នឹងនៅតែព្យាយាមស្វែងយល់ ពីបញ្ហានិងព្យាយាមជួយព្យាបាលខ្លួនឯងបន្តទៀត ។ ទៅថ្ងៃអនាគតអ្នកស្រីគិតថាមិនចង់ប្រកបរបរអកស៊ីអ្វីទៀតទេ អ្នកស្រីនឹងជួយ មើលថែចៅៗ ដើម្បីឲ្យកូនៗប្រឹងប្រែងរកស៊ី ។

Ms. Pen Sokchan

Ms. Pen Sokchan, 51, lives at Beoung ChhoukVilllage, Khna Tor Teung commune, Bakan district, Pursat province. She is a poor peasant and a widow with six children: five girls and a boy, who is the youngest.

Before the Khmer Rouge era, Ms. Sokchan lived in Kampong Kdei Village, Outapong commune, Bakan district, Pusat province. Ms. Sokchan was the second child to her mother,who was a housewife and her father, who was a soldier. She could not go to school because the whole family had to move with the father, who was required to serve in the war in different locations. During the Khmer Rouge era, her family was evacuated from Kampong Kdei commune to Beoung Chhouk, a village where she now lives.

"I was scared to death and cried heavily", said Sokchan

As a youth during the Khmer Rouge regime, she was assigned to the women's mobile group, a forefront group whose job it was to produce fertilizer from human excrement and carry soil for building dams. After that, she was assigned the sole task of stirring human excrement using her bare hands and feet. "Turning 16 was the most painful year for me," said Ms. Sokchan. "The Khmer Rouge forced me to work even harder. I was separated from my parents and siblings and was forced to married someone I didn't know at a very early age. I witnessed with my own eyes, my father being dragged away. Although I did not see him being killed, I knew he was killed after they arrested him.To this day, disease or death suffered by neighbors, relatives or even people I don't know can cause me a lot of distress" she added.

When she returned from the rice field late one evening at around 9:30 to 10:00 pm in Dem Roka commune, in late 1978, Ms. Sokchan was told that she must marry a man she did not know – she did not even know his name. Fifteen couples were married by the KR against their will. Ms. Sokchan was the youngest— she had not yet reached puberty — of all the women (her development was delayed due to malnutrition and hard labour). "I was scared to death and cried heavily" said Sokchan. That night it rained heavily, allowing her to avoid being forced by the Khmer Rouge (KR) to consummate her marriage for the first night. On the second night, Ms. Sokchan was raped by her husband. She was slapped on the face and both of her hands were held tight underneath her back, as she laid flat on the floor facing up. Her clothes were forcefully removed. On the third night, she was so frightened that she resolved to run away and find her mother. Luckily, she found her mother.

For years, Ms. Sokchan never told her story of forced marriage, nor did she ever think of telling it to anybody. Her intention was to bury the story with her so that it remained secret forever. Now many people in her village, including her children, know about her forced marriage after she decided to film her biography for a documentary called "Red Wedding." Her children were shocked and surprised by her story, however, they turned to be very supportive of her decision to make the documentary.

She has never seen her husband since she escaped three days into the relationship. She later overheard that he was killed by the KR. In 1980, Ms. Sokchan remarried.

This marriage was different because it was agreed upon by the couple's parents. Her second husband was a soldier who had separated from the woman he had married during the KR era. The happy time– the time of love, understanding and intimacy– did not last for many years. The relationship became sour when they had their third child. She was beaten and abused sexually and emotionally because her husband committed adultery. Ms. Sokchan and all her children had to live with her mother.As a single parent with three children and an older mother to care for, Ms. Sokchan made a living as a peasant. In order for her to earn enough to feed her hungry family, she, also bought fruit from the village and transported it to sell at the town market. Poverty prevents her children– the four girls – from having a proper education. The whole family, now, is supporting the youngest son through higher education. Living in a violent marriage, Ms. Sokchan described the violence against her as being threatened with gunshot to the air and on the ground and /or pointed at her head. Her husband died in 1993. "If my husband was still alive, I would not be alive today...," said Ms. Sokchan. She did not remarry again, She says that she barely survived living in a domestically violent jail and would never want to be in this borderless jail again. She compared her married life and her life during the KR era as equally painful. Ms. Sokchan always avoids seeing and hearing about domestic violence.

In June 2011, Ms. Sokchan and other eight women with similar experience attended a self help group organized by CDP's GBV project. The self help group last for one year in which time the group members met each month. Ms. Sokchan was so happy with this support group because everyone seemed to be nice to and understand each other. The group and group activities contributed so much to the healing of her psychological wounds. The group meeting allows her to think deeply about her problems and gain strength to face her traumatic problems. Ms. Sokchan's favorite activity was drawing and the group discussion to find out possible solutions, and seek support for her problems. Her other favorite activities included fun exercises, the tree exercise, breathing exercises that helps her with her anger and ability to sleep, and the closing ritual using sand. She is determined to continue supporting members of the self-help group by continuing to meet them even at other social occasions. Ms. Sokchan believes that having a self-help group which consists of people with similar experiences is useful because they can share feelingsand support each other. The group activities made her see meaning in life and take action to stay healthy and look after herself. Ms. Sokchan noticed changes in herself as a result of joining the self help group, for example she feels more able to control her emotions, she feels less fearful and less frustrated, she has more patience and shows less violence towards the children. She doesn't keep things to herself as much and has learnt to express herself more often. She has gained weight and sleeps well. She wishes to encourage other survivors of forced marriage and sexual abuse to think positively about life and themselves, to stand up for themselves and seek support by not keeping the trauma to themselves.

To some extent, the bad dream continues to affect her daily life, however, she will continue to understand and accept her problems as well as continue to self- treat her psychological problem. Ms. Sokchan thinks of stopping work and becoming a grandma who looks after her grandchildren so that her children can focus on making money.

ឡាយ គឹមឈាន

អ្នកស្រី ឡាយ គឹមឈាន អាយុ ៥៤ឆ្នាំ រស់នៅភូមិក្រូចសើច ឃុំខ្ជារទទឹង ស្រុកបាកាន ខេត្តពោធិសាត់ ។ អ្នកស្រី ជាកសិករ និងជាស្ត្រីមេម៉ាយដែលមានកូន៦នាក់ ស្រី៤នាក់ និងប្រុស២នាក់ ។

កាលពីមុនសម័យខ្មែរក្រហមអ្នកស្រីរស់នៅភូមិថ្មី ឃុំណាច ស្រុកក្រវ៉ាញ ខេត្តពោធិសាត់ បន្ទាប់មកត្រូវ ខ្មែរក្រហម ជម្លៀសពី ស្រុកក្រវ៉ាញ មកក្រុង ពោធិសាត់ ។ មុនរដ្ឋប្រហារទម្លាក់សម្តេចសីហនុ គាត់មាន អាយុ ១៣ឆ្នាំ រៀនថ្នាក់ទី ១០ (ស្មើទី៣ បច្ចុប្បន្ននេះ) ។ ប៉ុន្តែក្រោយ រដ្ឋ ប្រហារមកគាត់មិន បានចូលរៀនទេ ព្រោះគេចាប់ព្តើមបិទសាលាមិនឲ្យ រៀន ។ នៅក្នុងឆ្នាំ ១៩៧៥ គាត់មានអាយុ ១៦ឆ្នាំ រស់នៅក្នុង ភូមិក្រូច សើច ឃុំខ្ជារទទឹង ដោយពេលនោះគាត់ត្រូវបានខ្មែរក្រហមចាត់ ឲ្យធ្វើការ ក្នុងកងមិត្តនារី កាប់ដី លើកប្រឡាយ រំក និងកូរលាយលាមកអាចម៉ ។ អ្នកស្រី ជាមិត្តល្អរបស់ អ្នកស្រី ប៉ែន សុខចាន់ រហូតមក ដល់ សព្វថ្ងៃនេះ ដោយសារតែដំឡូងមួយដុំដែលគាត់លួច លាក់ឲ្យ ពេលដែល អ្នកស្រី ប៉ែន សុខចាន់ លួចរត់ ចេញពីការ បង្ខំពីសំណាក់ប្តី ដែលបង្ខំឲ្យរៀបការ ។

នៅចុងឆ្នាំ ១៩៧៧ អ្នកស្រីត្រូវបានខ្មែរក្រហម បង្ខំឲ្យរៀបការជាមួយបុរស ដែលគាត់មិនស្គាល់ថាជានរណា ជាមួយនឹង គូដែលត្រូវបង្ខំ ៩គូ ទៀត (ទាំងអស់១០គូ ដែល៧គូជាស្ត្រីក្រមុំ និង៣គូជាស្ត្រីមេម៉ាយ) ។ ប្តីរបស់ គាត់មិនមែនជា មនុស្សដែលកាចសាហាវទេ ។ គាត់អាចរួចខ្លួន ៣យប់ បើទោះបីជាមានការតាម ជានពីល្លូប ក៏ដោយ ។ ប៉ុន្តែគាត់មិនអាចរួចខ្លួន រហូតនោះទេ នៅថ្ងៃទី ៤ គាត់ត្រូវបានខ្មែរក្រហម យកទៅកសាង ហើយ ប្រាប់ថា បើគាត់នៅតែមិន ព្រមរួមដំណេកជា មួយ ប្តីទេ គេនឹងវាស់ដីឲ្យ ដើរ ដែលនោះមានន័យថាស្លាប់ ។ អ្នកស្រីបញ្ជាក់ថាប្តីរបស់ គាត់ក៏ប្រ ហែលត្រូវគេហៅយកទៅណែនាំកសាងដែរ ។ យប់ថ្ងៃទី៤នោះ អ្នកស្រី ត្រូវបានប្តីបង្ខំ រំលោភដោយ ច្របាច់ការ និងហែកសំលៀកបំពាក់គាត់ រំលោភតែម្តង ។ រស់នៅជាមួយគ្នាបានប្រហែលជា២០ថ្ងៃ គាត់បានលួច រត់ចេញពីប្តី ទោះជាមានការបង្ខំឲ្យមករក ប្តីវិញក្នុងមួយសប្តាស៍ម្តង ក៏គាត់ ប្រើល្បិចមកមិនដល់ផ្ទះសុខចិត្តដេកសម្រាក តាមផ្លូវ រួចព្រឹកឡើងត្រឡប់ ទៅកន្លែងធ្វើការបស់ខ្លួនវិញដែរ ។ បន្ទាប់ពីគេដឹងថាអ្នកស្រីប្រើល្បិច ខ្មែរ ក្រហមក៏ឲ្យប្តីមករកគាត់វិញម្តង ។ ដោយសារ ខ្មាស់គេគាត់ក៏បានប្រាប់ ប្តីថាមិនឲ្យមករកគាត់ទៀតទេ ហើយក៏បែកគ្នារហូត ដល់បែកខ្មែរក្រហម ដើមឆ្នាំ ១៩៧៩ ទើបប្តីរបស់គាត់ទៅតាមរកគាត់មក សុំរស់នៅជុំគ្នាវិញ ។ ដោយមានការជួយអង្វរការពីសំណាក់ម្តាយ និង បងស្រី អ្នកស្រីក៏ព្រម មករួមរស់ជាមួយប្តីវិញ ។ រហូតមកដល់ពេលនេះ មានអ្នកភូមិជា មួយគ្នា ដែលរស់នៅក្នុងភូមិនេះតាំងពីសម័យខ្មែរក្រហមមកបានដឹងរឿងនេះ ហើយគាត់បាននិយាយប្រាប់កូនៗរបស់គាត់ពីការបង្ខំឲ្យរៀប ការនេះ ប៉ុន្តែមិន បាននិយាយពីការបង្ខំរួមដំណេកនោះទេ ព្រោះគាត់ មានការអៀនខ្មាស់ ។ នៅពេលដែលកូនៗដឹងរឿងនោះ ពួក គាត់បានសួរនាំបន្ថែម ប៉ុន្តែពួកគាត់ហាក់ ដូចជាមិនជឿ ។ អ្នកស្រីឡាយ គឹមឈានរស់នៅជាមួយប្តីបាន ៥ឆ្នាំ ហើយ បានកូនស្រីពីរនាក់ ក្នុងជីវិតរស់ដូចជាស្ត្រីមេម៉ាយ ព្រោះប្តី គាត់មិនសូវនៅផ្ទះទេ គាត់រស់នៅឯសមរភូមិប្រយុទ្ធ មិន រវី រវល់ជាមួយប្រពន្ធកូនពីការអត់ឃ្លាននោះទេ ។ អ្នកស្រី បាន និយាយថា " ... គេមករកយើងតែពេលគេត្រូវការរួមភេទទេ គេមិនខ្វល់ថាប្រពន្ធកូនយ៉ាងមេំចនោះទេ" ។ ក្នុងការរស់នៅ ជាមួយគ្នាជាប្តីប្រពន្ធរយៈពេល៥ឆ្នាំនោះ គាត់មិនដែលមាន អារម្មណ៍ថាស្រឡាញ់ប្តីបន្តិចសោះ ប្តីរបស់គាត់ ក៏មានស្រី ផ្សេងទៀតដែរ ។ ប្តីដែលបានបង្ខំឲ្យរៀបការរបស់ គាត់ជាទា ហ៉ានបានស្លាប់នៅឆ្នាំ ១៩៨៣ ដោយសារខ្មែរ ក្រហម បាញ់ សម្លាប់ពេលប្រយុទ្ធគ្នានៅសមរភូមិខ្សែត្រៀម។ ឆ្នាំ ១៩៨៥ អ្នកស្រី បានរៀបការប្តីថ្មី ដោយមានការស្តីដណ្តឹង ដឹងឲ្យពី ចាស់ទុំ ។ អ្នកស្រីស្រឡាញ់ ពេញចិត្តនឹងទំនាក់ទំនង ជាមួយ ប្តីក្រោយនេះណាស់ គាត់ជាមនុស្សល្អ ស្រឡាញ់ប្រពន្ធកូន

ជួយធ្វើស្រែចំការ រកស៊ីចញ៉ីមគ្រួសារ ។ នៅឆ្នាំ ១៩៩៧ប៉ុរបស់អ្នកស្រីបានស្លាប់ដោយសារជម្ងឺ គ្រុនចាញ់ និងគ្រុនឈាម នៅពេលដែលគាត់ត្រឡប់មកពីកាប់ឈើ និងរកអុស ។ ទោះជាបានចំណាយលុយជាច្រើនដើម្បីព្យាបាលប្តី ក៏នៅតែមិនអាចរក្សាជីវិតបានដែរ ។ អ្នកស្រីបានក្លាយជាស្ត្រីមេម៉ាយទទួលបន្ទុកកូន ៦នាក់តែម្នាក់ឯង ប្រកបរបរធ្វើស្រែចំការ ភ្ជួរ រាស់ដកស្ទូង ដាំបន្លែដើម្បីយកទៅលក់ ជាមួយកូនៗរហូតមក ។ ដោយសារបញ្ហាជីវភាព កូនៗរបស់គាត់មិនបានរៀនសូត្រទេ ។ អ្នកស្រី និងប្តីស្រឡាញ់កូនៗទាំងអស់ស្មើរគ្នា មិនបានគិតថាកូនមុន ឬកូនក្រោយអ្វីនោះទេ ។

ដោយសារតែសង្គ្រាមធ្វើឲ្យអ្នកស្រីមិនសូវមានសុខភាពល្អម៉ាំទាំនឹងគេនោះទេ ដែលជាហេតុធ្វើឲ្យប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារដែរ ។ ពីមុនអ្នកស្រីតែងតែយល់ថាខ្លួនឯងមិនមានតម្លៃ តែងតែប្រៀបធៀបខ្លួនឯងទៅនឹងអ្នកដទៃ ដោយសារតែខ្លួនរស់នៅកំព្រាគ្មាន ខ៉ឹពុកម្តាយបងប្អូនត្រូវគេបង្ខំឲ្យរៀបការទើបគេមិនឲ្យតម្លៃ ហើយអភ័ព្វយ៉ាងនេះ ។ អ្នកស្រីធ្លាប់គិតចង់សម្លាប់ខ្លួនជាច្រើនដង ដោយសារតែពិបាកចិត្ត ឈឺថ្កាត់និងទទួលបន្ទុកគ្រួសារតែម្នាក់ឯងពេក ។

ការសម្លាប់ជាក្រុមដែល ឡាយ គឹមឈាន បានឃើញផ្ទាល់ភ្នែក

នៅពេលបានចូលរួមជាមួយក្រុមជួយខ្លួនឯង គាត់យល់ថា ខ្លួនឯងមានចិត្ត និងគំនិតទូល់ទូលាយជាងមុន ហើយមានអារម្មណ៍ធូរសាប្រជាងមុនដែរ ។ គាត់បានបោះបង់ចោលគំនិតចង់សម្លាប់ខ្លួន ដោយខំប្រឹងប្រែងរស់នៅថែរក្សាសុខភាពឲ្យល្អ ។ គាត់ពេញចិត្ត នឹងទំនាក់ទំនងក្នុងក្រុម ការជឿទុកចិត្ត និងការយល់ចិត្តគ្នា ។ សកម្មភាពនានាពីការសម្របសម្រួល និងស្មារតីក្រុមទាំងមូល ធ្វើឲ្យគាត់ជឿជាក់អាចនិយាយចែកវំលែករឿងំរាវល់បាកៗរបស់ខ្លួនបាន ធ្វើឲ្យគាត់ធូរស្បើយរសាយចិត្ត ។ នៅពេលជួបប្រជុំគ្នាម្តងៗ អ្នកស្រីចូលចិត្ត ការជជែកពិភាក្សាគ្នាដើម្បីចែកវំលែកកង្វល់ក្នុងចិត្ត សកម្មភាពគូរូបនានាជាពិសេសគំនូរលើល់ហាត់ស្ទឹងជីវិត និងដើមឈើ សកម្មភាពដើរលេងកំសាន្ត និងពិធីបិទដោយប្រើដីខ្សាច់ ។ អ្នកស្រីគិតថាការចងក្រងជាក្រុមរវាងអ្នកដែលមានបទពិសោធន៍ ឈឺចាប់ស្រដៀងគ្នាបែបនេះពិតជាមានប្រយោជន៍ណាស់ព្រោះអាចជួយរិតចំណងមិត្តភាពរបស់ពួកគាត់ គាត់អាចពិភាក្សាគ្នា ជួយចែក រំលែកទុក្ខគ្នាបាន ។ អ្នកស្រីយល់ថា គាត់ខុសប្លែកពីមុនបានចូលរួមជាមួយក្រុមនេះ ដោយយល់ថាខ្លួនគាត់មិនមាន អារម្មណ៍ឯការដូចមុន ភ្ជឺថ្លាស្រឡះខួរក្បាលសំរាន្តលក់ជាងមុន បើកចិត្តទូលាយជាងមុន ចេះរំងាប់អារម្មណ៍ និងអត់ធ្មត់ជាងមុន ជាពិសេស ទាំងអស់នេះ បានធ្វើឲ្យគាត់មិនដែលមានគំនិតចង់សម្លាប់ខ្លួនទៀតទេ ។ អ្នកស្រីមានប្រសាសន៍ថា "អតីតកាលរបស់ខ្ញុំលែងឈឺចាប់ដូចមុន ទៀត ហើយ ដោយខ្ញុំបានរៀនចេះនឹងជាងមុន ស្គាល់គ្នាច្រើន មានគ្នាចែកវំលែកអារម្មណ៍ ស្គាប់លោកទេសនាគិតវិជ្ជមានពីជីវិត ។ល។"

អ្នកស្រីចង់ផ្តាំទៅជនរងគ្រោះពីការបង្ខំឲ្យរៀបការ និងការរំលោភបំពានផ្លូវភេទដទៃទៀតថា សូមកុំព្យាយាមលាក់លៀមការឈឺចាប់ តែម្នាក់ឯងទៀតអី ការឈឺចាប់មានដូចគ្នា កុំគិតថាមានតែម្នាក់ឯង សូមរឹងមាំឡើង ។

អ្នកស្រីយល់ថាជីវិតរបស់អ្នកស្រីសព្វថ្ងៃមានភាពសប្បាយរីករាយច្រើន ប្រទេសមានសន្តិភាព មានសាលារៀនឲ្យកូនចៅបានទៅរៀន មានមន្ទីរពេទ្យ ជាពិសេសមានសេរីភាព ។ អ្នកស្រីគិតថាទៅថ្ងៃអនាគតនៅពេលដែលកូនៗរបស់គាត់រៀបការអស់ ឃើញគេមាន អនាគតល្អ គាត់នឹងនៅជួយមើលថែទាំចៅៗ និងទៅវត្តខំប្រឹងសន្សំបុណ្យកុសលដើម្បីឲ្យជាតិមុខល្អ កុំឲ្យជួបអ្វីដែលបានកើតឡើង ក្នុងជាតិនេះទៀត ។

Ms. LAY Kimchhean

Ms. LAY Kimchhean, 54, is a widow lives in KrouchSerch village, KhnaToteung Commune, Bakan district, Pursat province. She is a peasant with three daughters and two sons.

Before the Khmer Rouge era she lived in Thmey village, Leach commune, Kravanh district, Pursat commune. Later she was forced to evacuate to Pursat town. Before the coup against King Sihanuok, she was 13 years old and was in grade 10 at school (the equivalent of grade 3 today). Following the coup, however, she was no longer able to attend school as all schools were closed. In 1975 she was 16 years old and lived in Krouch Serch village, KhnaToteung commune where she was assigned to the mobile women's group. The mobile women's groups were required to build dams and make fertilizer by stirring human stool. Ms. Kimchhean is a close friend of Ms. PEN Sokchan because of a piece of potato that she stole and hid from Angka to give to Sokchan when she escaped from her forced marriage.

Towards the end of 1977 Ms. Kimchhean was forced to marry to a man who she had never met. The marriage took place with nine other couples (Ten pairs in total; of the women, seven were virgins and three were widowers). Her new husband was not a cruel man initially. Although the Khmer Rouge (KR) cadre were on watch, she was lucky that she was not forced to consummate the marriage for the first three days. On the fourth day however,she was taken for'education'by the KR and told that if she didn't agree to have sex with her husband they would draw a line for her to walk, which meant that they would kill her. They also threatened that her husband might be taken for 'education' by Angka. That night, she could not avoid it anymore; she was raped by her husband who at first tried to strangle her, then tore her clothes. After living with him for about three weeks she ran away from her husband to live in another cooperative. She was lucky that Angka didn't kill her but instead told her that she must visit and stay with her husband once a week. Ms. Kimchheanpretended to visit her husband, but in order to avoid seeing him instead slept on the way and returned to her cooperative in the morning. When Angka found out about this, they told her husband to come and meet her instead. When her husband came to see her, she felt ashamed in front of the other women and told him not to come again. They did not meet again until early 1979 when he came to her and asked her to reunite with him. Following pressure from her mother and older sister she agreed to return to him.

To this day, the residents of this village who have lived there since the KR era know about Ms. Kimchhean's forced marriage. She has also talked to her children about the forced circumstances of her marriage but is too ashamed to tell them about the circumstances in which the marriage was consummated. When the children heard this story they asked for more information but they did not seem to believe it. Ms. Kimchhean spent five years in the relationship and had two daughters with her husband through forced marriage.

Her five years with him was like living as a widower as she spent most of this time living in the military base where he was a soldier and was only able to visit sometimes when the commander allowed it. He lived far away and never showed concern nor care for his family about whether they had enough food to eat orif anything happened to them. She said that "...he came to me only when he needed sex. He never cared what happened to his wife and children". In the five years of their relationship she never felt any love for him. He also had affairs with a few other girls in this time. He died in 1983 during combat with KR soldiers at the front line.

In 1985 Ms. Kimchhean remarried another man following agreement by the parents. She liked her new husband a lot because he was a good man. He loved her and the children. He helped out with household work and was a hard-working person. Sadly, he died of malaria and dengue fever in 1997 after returning from the forest where he had been cutting wood. Although she spent a lot of money trying to treat his condition she was unable to save his life. She became a widower once more with six children under her care and responsibility. She had to work harder at both men's and women's work,both in the rice fields and growing vegetable and crops to sell in the market with her children in order to make a living. Because of the economic problems she could not afford to send her children to school. The relationships between her and all of her children is good. Both her and her second husband treated the children from her forced marriage equally.

Ms. Kimchhean feels that, as a result of the war, she isn't in a good health which has a big impact on the family finances. Before joining the self-help group she always felt like she was not a valuable or strong person, and would always compare herself to other people, getting upset because she felt lonely, weak, as she was forced to marry. She thought that because of these reasons people did not value her as a person. She felt like she was an unfortunate person. She used to regularly experience suicidal thoughts when she was stressed or sick and especially when she thought about her huge responsibility to the family.
When she joined the self-help group she began to feel a lot better. She stopped having suicidal thoughts and she tries her best to stay in good health. She loves the empathetic and trusting relationship that exists between her group members.

"...he came to me only when he needed sex. He never cared what happened to his wife and children".

The group activities and team spirit that exists between group members encouraged her to trust the other members and share the difficulties that she has experienced in life, which is a great relief to her. In every meeting she enjoyed the time spent sharing difficult experiences where the group would listen and show support. She also enjoyed engaging in some drawing and painting activities including drawing the river of life and the tree, the tour in the city and the closing ceremony which involved using a sand tray. She thinks it is very useful to establish a group of people who share similar experiences like this group because it greatly helps in strengthening group member's relationships, and provides a space in which they can discuss and share their concerns.

She thinks that she is a lot different compared to before she joined the group as she feels her mind is more relaxed, she sleeps better, is more open-minded and patient and has let go of her anger. Importantly, she no longer experiences thoughts of self harm or suicide. "I do not suffer from my past as much as before because I have more knowledge, I know more people who I can share my difficulties with, I listen to monk chanting and advice, and i think more positive thoughts about life, etc." said Ms. Kimchhean.

She wants to tell other survivors of forced marriage and sexual abuse not to hide or keep their pain to themselves as there are many any people suffering the same thing. Be strong!
She thinks that her life nowadays is a lot happier, the country is stable and peaceful, schools and hospitals are accessible everywhere, and most importantly there is freedom. She thinks that in the future when all her children are married she will help them and care for her future grandchildren. She goes to the pagoda whenever she wants to pray for goodness for this life and the next.

គំនូរស្ទឹងជីវិត

River of life drawing

ឧឿក សំ

អ្នកស្រី ឧឿក សំ អាយុ៥៨ឆ្នាំ ជាស្ត្រីមេម៉ាយរស់នៅភូមិជើមរការ ឃុំខ្នារទទឹង ស្រុកបាកាន ខេត្តពោធិសាត់ មានមុខរបរជាអ្នកជើរទិញអេតចាយ និងធ្វើស្រែបន្តិចបន្តួច ។ អ្នកស្រីមានកូន ៧នាក់ ប្រុស៤នាក់ ស្រី៣នាក់ ។ មុនសម័យខ្មែរក្រហមគាត់រស់នៅភូមិផ្ទះស្លា ឃុំខ្នារទទឹង ខេត្តពោធិសាត់ មានរបរជាកសិករ ។

ក្នុងសម័យខ្មែរក្រហមអ្នកស្រីត្រូវបានគេជម្លៀសឲ្យទៅរស់នៅភូមិស្ទាយកន្ទៀង ឃុំគន្ធា ស្រុកបាកាន ខេត្តពោធិសាត់ ។ ស្ថិតនៅក្នុងក្រុមធ្វើស្រែ មិនយូរប៉ុន្មាន គាត់ត្រូវគេថ្លាស់ឲ្យទៅនៅក្នុងក្រុមកងស្នែងជើម្បីសែងអ្នករងរបួស និងអ្នកស្លាប់ក្នុងសមរភូមិ ។ អ្នកស្រីត្រូវបានខ្មែរក្រហមចាប់ជាក់គុក ធ្វើទារុណកម្មស្ទរចម្លើយ ដោយចោទប្រកាន់ថា គាត់ក្បត់អង្គការ ថាជាក្រុម KGB វៀតណាម។ គាត់ត្រូវបានខ្មែរក្រហមធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរស្ទើរៈល់ថ្ងៃ ដោយវាយដំ និងប្រើខ្សែភ្លើងឆក់ បង្ខំឲ្យគាត់ឆ្លើយសារភាព ប៉ុន្តែគាត់មិនឆ្លើយព្រោះគាត់មិនបានក្បត់នឹងអង្គការ មិនដឹងឆ្លើយរបៀបណា គ្រាន់តែឆ្លើយថា គាត់ស្មោះត្រង់នឹងបដិវត្តន៍ មិនដែលក្បត់នឹងអង្គការទេ ។ អ្នកស្រីត្រូវបានខ្មែរក្រហម ជាក់គុកអស់រយៈពេលជាងមួយខែរស់នៅជាប់ច្រវាក់ជើងរហូត ។ បន្ទាប់ មកគាត់ត្រូវបានគេដោះលែង ឲ្យទៅធ្វើការជា អ្នកជាំ បាយឲ្យអ្នកទោសដទៃទៀតដែលនៅមិនទាន់បានរួចខ្លួនដូចគាត់ ប្រហែលមួយខែក្រោយមក គេ បានបញ្ជូន គាត់ឲ្យទៅរស់នៅសហការភូមិអាជ៉ែនទទួលការងារមើលថែទាំក្មេង និងជាំបន្លែ ។ ថ្ងៃមួយពេលកំពុងកាប់ជីជាំបន្លែ ក្នុងខែមករា ឆ្នាំ១៩៧៧ មានន៊ិរសារម្នាក់ បានមកហៅគាត់ឲ្យឡើងជិះ រថយន្តមួយ ហើយបានប្រាប់គាត់ថាមេសហការហៅឲ្យទៅជួប ។ ពេលនោះអ្នកស្រីភ័យស្ទើរលោះព្រលឹងពីព្រោះ រថយន្តមួយនោះជារថយន្តដែលចំណាំតែជឹកមនុស្សទៅសម្លាប់ អ្នកស្រីបានគិតថា នោះជាពេលចុងក្រោយនៃជីវិតរបស់គាត់ហើយ ។ ពេលទៅដល់ផ្ទះបាយក្នុងភូមិអាជ៉ែន ស្រុកបាកានម៉ោងប្រហែល ៤ល្ងាច អ្នកស្រីត្រូវបានប្រធានសហការណ៏ប្រាប់ថាត្រូវរៀបត្រូសារ ដោយមិនបានដឹងថានឹងរៀបការជាមួយនរណា មិនដែលស្គាល់គ្នាពីមុនសោះនោះ ។ នៅថ្ងៃគាត់រៀបការនោះមាន ៧គូ យប់នោះគាត់ព្រមស្រុះស្រួលរស់នៅជាមួយប្តី ព្រោះខ្លាចត្រូវគេយកទៅសម្លាប់ ។ មកដល់ឆ្នាំ ១៩៧៩ នៅពេលបែកខ្មែរក្រហម ប្តីបានសុំបែកបាក់គ្នាពីអ្នកស្រី ព្រោះគាត់សុំទៅរស់នៅជាមួយឪពុកម្តាយគាត់វិញ បើទោះបីជាគាត់មានកូន ពីរនាក់ (ប្រុស១ ស្រី១) ជាមួយគាត់ក៏ដោយ ។ មកដល់ពេលនេះកូនៗ និងអ្នក ភូមិទាំងអស់សុទ្ធតែ បានដឹងពីរឿងការបង្ខំឲ្យរៀបការរបស់អ្នកស្រី ហើយពួក គេមានតែសម្តែងអារម្មណ៍ដូចជាអាណិតអាសូរ និងស្ងើចសរសើរគាត់ទៅវិញ ដោយសារការខំប្រឹងតស៊ូចិញ្ចឹមកូនរបស់គាត់ ។ អ្នកស្រីបានរៀបការម្តង ទៀតក្នុងឆ្នាំ ១៩៨៥ ។ ទំនាក់ទំនងរបស់គាត់នឹងប្តីក្រោយនេះ ល្អជាមួយ គ្នាតែពេលទើបរៀបការដំបូងប៉ុណ្ណោះ ពេលនោះពួកគាត់ស្រឡាញ់គ្នាចិត្តនឹងចិត្ត ចេះយល់ទុក្ខធុរៈគ្នា ប៉ុន្តែមិនដឹងមានមូលហេតុអ្វីទេគាត់ចេះធឹកស្រា ហើយចាប់ តាំងពីគាត់ចេះធឹកស្រាមកគាត់បានប្រើហ៊ិង្សាខ្លាំងជាក់អ្នកស្រី និងកូនៗ ។

បរិមាណនៃការផឹកស្រារបស់គាត់ក៏កើនឡើងពីមួយថ្ងៃទៅមួយថ្ងៃរហូតដល់ស្រវឹងរាល់ថ្ងៃ ហើយបានស្លាប់ក្នុងដើមឆ្នាំ ២០១០ ដោយសារលង់ទឹកស្លាប់ ។ អ្នកស្រីឆ្លាប់បានមានប្រសាសន៍នៅក្នុងជំនួបក្រុមថា គាត់ហាក់ដូចជាធូរចិត្ត សប្បាយចិត្តជាងមុនច្រើន តាំងពីប្តីរបស់គាត់ស្លាប់ទៅព្រោះគ្មានអ្នកធ្វើបាបទាំងកាយទាំងចិត្ត ។ សុនភាពផ្លូវកាយ និងផ្លូវចិត្តរបស់គាត់ហាក់ដូចជាមានភាពប្រសើរឡើងច្រើនជាងមុនពេលដែលនៅជាមួយប្តី ។ ទំនាក់ទំនងរបស់គាត់និងកូនៗ ដែលបានមកពីការបង្ខំឲ្យរៀបការទាំងពីរនាក់ នោះគឺល្អដូចគ្នាជាមួយនឹងកូនៗដែលរៀបការក្រោយដែរ ពួកគេគេយកចិត្តទុកដាក់និងបារម្ភពីគាត់ណាស់ ។ ចាប់តាំងពីចប់សង្ត្រាមមកអ្នកស្រី ខ្យឹក ស៉ ប្រកបរបររកស៊ីលក់ដូរតិចតួចនៅផ្ទះ ។ ទោះបីជារបបខ្នែរក្រហមត្រូវបានដួលរលំប៉ុន្តែនៅមិនទាន់មានសន្តិភាពស្ថេរភាព ពេញលេញនៅឡើយទេ នៅតែមានការបាញ់បោះរវាងក្រុមទាហ៉ានប៉ាក៉ា និងទាហ៉ានរៀតណាមនៅឡើយ រហូតដល់ឆ្នាំ១៩៩៨ ទើបស្ងប់ស្ងៀម ។ អ្នកស្រីនិងក្រុមគ្រួសារឆ្លាប់ត្រូវបានក្រុមចោរព្រៃមួយក្រុមចូលប្លន់ វាយធ្វើបាបគាត់និងប្តី ហើយយកទ្រព្យសម្បិត្តិ អស់រលឹង ។ រហូតមកដល់សព្វថ្ងៃនេះអ្នកស្រីនៅតែមានការភ័យខ្លាច បាក់ស្បាតដោយសារតែរឿងនោះ ដែលនាំឲ្យគាត់តែងតែមាន ការប្រយ័ត្នប្រយែងខ្ពស់ និងភ័យខ្លាចស្នើររឿងរាល់យប់ ។
អ្នកស្រីយល់ថាសង្ត្រាមក្នុងនោះមានការបង្ខំឲ្យរៀបការផង នោះបានធ្វើឲ្យ ប៉ះពាល់ដល់ជីវិត ផ្លូវចិត្តរបស់គាត់យ៉ាងខ្លាំង ពុំមានសេរីភាពក្នុងការសម្រេចចិត្ត គាត់នៅតែមានអារម្មណ៍ថាសោក ស្តាយ តូចចិត្ត ព្រោះគ្មាននៅសល់បងប្អូនសាច់ញាតិនិងគេ និងមានការខ្វះខាតក្នុងជីវភាពរស់នៅ ។ អ្នកស្រីយល់ថាក្រុមរបស់គាត់ទាំង ៨នាក់នេះ ជាក្រុមដែលមានទំនាក់ទំនងល្អ ជឿទុកចិត្តគ្នា ធ្វើឲ្យគាត់មានអារម្មណ៍សប្បាយចិត្តច្រើន ហើយមានអារម្មណ៍ថាធូរស្រាល ដោយសារ ក្រុមទាំងមូលបានរួមគ្នាជួយផ្តល់មតិយោបល់ល្អៗ ជាពិសេសនៅពេលដែលគាត់មានអារម្មណ៍ស្មុគស្មាញពិបាកចិត្ត ។

សកម្មភាពក្រុម និងសមាជិកក្រុមទាំងអស់បានរួមគ្នាជួយគាំទ្រ និងលើកទឹកចិត្តគាត់ធ្វើឲ្យគាត់មានកម្លាំងចិត្តដើរទៅមុខទៀតជាមួយនឹងការលំបាក ទាំងឡាយ ។ សកម្មភាពដែលអ្នកស្រីចូលចិត្តមានដូចជាការលេងល្បែងដែលបង្កប់ដោយន័យអប់រំជាច្រើន ការធ្វើលំហាត់ប្រាណ ការ គូររូប ការលេងដីខ្សាច់ ។ល។ អ្នកស្រីគិតថានឹងនៅតែបន្តជួយគាំទ្រសមាជិកក្រុមរបស់គាត់តទៅទៀត ដើម្បីជួយដោះស្រាយ វិបត្តិ ផ្លូវចិត្តឲ្យបានគ្រប់ៗគ្នា ហើយគាត់គិតថានឹងនៅតែបន្តជួបគ្នាឲ្យបានញឹកញាប់បើទោះជាក្រុមនេះ បានបញ្ចប់ក៏ដោយ ។ គាត់យល់ ថាតាមរយៈការស្តាប់ និងពាក្យសម្តីជួយណែនាំ ទើបធ្វើឲ្យយើងបានសប្បាយធូរអារម្មណ៍ ។ គាត់គិតថាការចងក្រងជាក្រុមរវាងអ្នក ដែលឆ្លាប់មានបទពិសោធន៍ឈឺចាប់ដូចគ្នាបែបនេះ មានប្រយោជន៍ណាស់ព្រោះអាចឲ្យពួកគាត់ចែករំលែកអារម្មណ៍ឈឺចាប់ សប្បាយចិត្តនៅពេលជួបជុំគ្នាម្តងៗ ពង្រឹងទំនាក់ទំនងចាស់ៗ និងបង្កើតទំនាក់ទំនងថ្មីៗ ។ អ្នកស្រីយល់ថា ខ្លួនគាត់ដូចជាខុសប្លែក ពីមុនបានចូលរួមជាមួយក្រុមជួយខ្លួនឯងមួយនេះ ដោយពីមុន គាត់ថាខ្លួនគាត់ជាមនុស្សស្មុគគិតអ្វីមិនចេញ កើតទុក្ខរាល់ថ្ងៃ មានពេល ខ្លះគិតចង់សម្លាប់ខ្លួន ប៉ុន្តែឥឡូវគាត់សប្បាយចិត្តរីកភយច្រើន អត់ធ្មត់ច្រើន ពេលខ្លះធ្វើមិនដឹងមិនភ្ញរឿង ខ្លះទើបបាននាំឲ្យមិនសូវខឹង ឬខ្ទល់ខ្ទាយចិត្តពេក ។

អ្នកស្រី ខ្យឹក ស៉ ចង់រួមចំណែកជួយជនរងគ្រោះពីការបង្ខំឲ្យរៀបការ និង ការ រំលោភបំពានផ្លូវភេទដទៃទៀត ដោយបាននិយាយថាគាត់ចង់ជួបពួកគេជួយនិយាយណែនាំឲ្យពួកគេបានសប្បាយរីកភយដូចគាត់ដែរ ហើយឆ្លាំផ្ទើរទៅពួកគេថាសូមគិតវែងឆ្លាយពីអនាគតកុំគិតចង់សម្លាប់ខ្លួន ។ អ្នកស្រី ខ្យឹក ស៉ ពេញចិត្តនឹងអ្វីដែលគាត់មាន និង ជីវិតរស់នៅនាពេលបច្ចុប្បន្នរបស់គាត់បើទោះជាគាត់មិនមែនជាអ្នកមានម្នាក់ក៏ដោយ គាត់នឹងខំប្រឹងព្យាយាមធ្វើការតាមកម្លាំងរបស់ គាត់ ព្រោះជួប្នេះធ្វើឲ្យគាត់សប្បាយចិត្ត ។ ទៅថ្ងៃអនាគតអ្នកស្រីចង់ឃើញកូនៗមានគ្រួសាររកស៊ីរីកចម្រើន ហើយគាត់ចង់សម្រាកពី ការងារនៅតែធ្វើការផ្ទះតិចតួច និងទៅវត្តស៊ុសីល ។

Ms. DEOUK Sam

Ms. DEOUK Sam is 58 years old. She is a wido who lives in Derm Roka village, KhnaToteng commune, Bakan district, Pursat province. She is farmer and a rubbish collector, collecting recycled materials. She has seven children; four males and three females. Before the Khmer Rouge era she lived in Phtes Sla village, Khna Toteng commune, Pursat province where she worked as a farmer.

During the Khmer Rouge era, Ms. Sam was evacuated from her home village to Svaykantreang village, Kunthea commune, Bakan district, Pursat province where she worked with the farmer groups. After a short time she was told to move to the carrying group where she was required to carry the people who had been killed or wounded in the fighting. She was then put in prison and severely tortured by Khmer Rouge (KR), who accused her of being a member of the Vietnamese KGB – a traitor to Angka. Almost every day, she was severely tortured by KR who administered electric shocks and beat her in order to force her to confess that she was a traitor to Angkar. Despite these torture tactics, she refused to make these false confessions and instead answered that she would never betray Angka and was always faithful to the revolution. During the course of her one month imprisonment she was handcuffed every day. Later she was released to work as a cook for the other prisoners.

About one month later the KR transferred her to Aren village Corporation to look after the children and grow vegetables. One day in January 1977, while she was tending to her vegetables, a messenger (KR cadre) arrived who ordered her to get on a truck which would take her to meet the chief of the corporation. At that moment, she felt as if her soul was flying away from her body because she recognized the truck as the same vehicle that normally drove people to the killing sites. She thought that was going to be one of the last moments of her life. When she arrived at the kitchen of Aren village at about 4 p.m., however, she was told by the chief of the corporation that she must get married to somebody she had never met. There were seven other couples arranged to be married at the same time. That night she agreed to consummate her marriage as ordered by Angka because she was scared that Angka would kill her. Just after the liberation in January 1979, her husband (through forced marriage)decided to leave her and go back to his mother despite the fact that by then they had two children together (one girl and one boy).
To this day, everyone in her village including her children know about the forced marriage between her and her (now) ex-husband and they are compassionate towards her and admire her for her hard work in raising the children.

In 1985 Ms. Sam remarried. The relationship between her and her second husband was only happy for the first few years.They loved, understood and helped each other and she is unsure why her husband began to drink alcohol and act violently to her and her children. Over time, his alcohol consumption increased to the point that he was drunk and beat her and the children on a daily basis.

As a result of his heavy drinking he drowned. She used to say in the group that she found herself happier since her husband's death because nobody hurt her physically and emotionally anymore. Her physical and emotional condition seemed to improve a lot compared to the time when she lived with her drunken and abusive husband. The relationship between her and her children from the forced married is as good as her relationship with the children from her second marriage. She loves them and they love and care for their mother a lot.

When the war ended Ms. Sam earned her living by running a small shop from home. Although the KR regime had collapsed, Cambodian society was still not stable or peaceful throughout the country. There was still fighting between the Para, the Vietnamese and the government soldiers up until the national reintegration took place in 1998. It was not until then that the country became stable, although a lot of robberies continued to happen. Her family was robbed by a group of robbers that broke in to her house at night, tied her and her husband up, beat them with a gun, then stole every item she owned. This incident continues to have a huge effect on her life today. She is full of fear nearly every night since that incident happened. This makes her very anxious and she always feels on guard. Ms. Sam believes that the war (including her forced marriage) has had a huge impact on her life especially in relation to her physical and mental well-being. Freedom to make decisions about anything, and a life free of poverty and hardship - these were taken away from her by war. She also continues to feel sadness about being an orphan and having no relatives.

Ms. Sam said that the eight members of the self-help group make it a good group which fosters strong and trustworthy relationship that makes her feel happier. She feels relief from having a chance to share her difficulties and stress with the group, especially when other group members offer her good ideas to deal with her problems. The group activities and members have contributed a lot in terms of supporting and her to move forward with the difficulties in her life. The activities that she likes the most include the learning-related exercises, body exercises, breathing exercises and art exercises such as drawing , painting, sand tray, etc.

Ms. Sam thinks that she will continue to be involved in the group in order to help the other group members feel better and feel supported in dealing with their emotional wounds. Although the group activities organized by CDP have finished, she thinks that she will continue to facilitate the group by trying to meet more often. She said that by sharing her experiences with the group members who are good listeners and receiving constructive comments from them continues to help her to feel much better. She thinks that having a group of people that have experienced trauma and share similar suffering such as this is very useful because the group members are able to share their experiences and difficulties, and as a result strengthen existing relationships and build new ones. Ms. Sam sees herself differently since joining this group. Before joining the group, she felt that she was a complicated person constantly experiencing difficulty, to the extent that at times, she contemplated committing suicide.

Now she is happier, has more patience, and at times can actively decide not to concern herself with problems which help her to be less angry and worried. Ms. Sam would like to meet other survivors of forced marriage and sexual abuse and speak with them in the hope of making them happy like her. She would like to tell them not to contemplate suicide as they have a better future to plan for.

Although she is not one of the richer families in her village, Ms. Sam is satisfied with her current situation in life. She is going to work as she can afford do it. She can relax if she doesn't feel well to work or she can take rest whenever she wants because only doing this she can feel happy with herself. In the future she wants to see her family especially her children grow with a secure economy while she lives her life just doing some house work and going to the pagoda.

ហេង គុយឡាង

អ្នកស្រី ហេង គុយឡាង អាយុ ៥៧ឆ្នាំ រស់នៅភូមិអូរទុក ឃុំកំពង់ក្រាង ស្រុកសង្កែ ខេត្តបាត់ដំបង ។ គាត់មានកូន៧នាក់ ស្រី ៤នាក់ ប្រុស៣នាក់ មានមុខរបរជាកសិករ និងស៊ីឈ្នួលធ្វើកូនគាំប៊ិត (ចុងភៅរង) ឲ្យគេម្តងម្កាលនៅពេលមានវល់ការ បុណ្យនៅក្នុងភូមិ ។

កាលពីមុនសម័យខ្មែរក្រហម គាត់រស់នៅស៊ីឈ្នួលបម្រើនៅផ្ទះគេនៅទួលស្វាយព្រៃ រាជធានីភ្នំពេញ ហើយបន្ទាប់មកពេលខ្មែរក្រហមចូលភ្នំពេញឆ្នាំ ១៩៧៥ គាត់ត្រូវបានជម្លៀសឲ្យទៅរស់នៅក្នុងភូមិដុង ខេត្តតាកែវ ធ្វើការងារ ដកស្ទូង លើកភ្លឺ លើកទំនប់ជីកប្រឡាយ ។ បន្ទាប់មកអ្នកស្រីក៏បានគេជម្លៀស ក្នុងផ្លូវយ៉ាងឆ្ងាយ មកស្រុកមុខកំពុល ខេត្តកណ្តាល បានប្រហែល៦ខែ ក៏ត្រូវគេជម្លៀសមកដល់បាត់ដំបង ។ ក្នុងខែមីនា ឆ្នាំ១៩៧៧ ម៉ោងប្រហែល ៩ ព្រឹក គាត់ត្រូវបានខ្មែរក្រហមបង្ខំឲ្យរៀបការនៅក្នុងឃ្លាំងអង្ករនៃផ្ទះកម្មាភិបាល ក្នុងភូមិថ្មី ឃុំកំពង់ក្រាង ស្រុកសង្កែ ខេត្តបាត់ដំបង ជាមួយនឹង ២គូផ្សេងទៀត ។ អ្នកស្រីមិនដែលស្គាល់ប្តីរបស់គាត់ពីមុនទេមុនរៀបការនោះ គឺរៀបការដោយសារការបង្ខំប៉ុន្តែក៏បានរួមរស់ជាមួយគ្នារហូតដល់បច្ចុប្បន្ននេះ ។ ទំនាក់ទំនងរបស់អ្នកស្រី និងប្តីមិនល្អនោះទេ ការរៀបការនោះ

គឺគ្រាន់តែជាការរៀបការដើម្បីគេចវេសពីការសម្លាប់ ហើយក្រោយមកគាត់ត្រមរស់នៅជុំជាមួយនឹងប្តី ដោយសារតែការអាណិតអាសូរកូនៗ ពុំមានការស្រឡាញ់រាងប្តីប្រពន្ធអ្វីទេ ម្យ៉ាងដោយសារគាត់ជាក្មេងកំព្រាគ្មានបងប្អូនសាច់ញាតិពឹងពាក់នឹងគេ ។ អ្នកស្រីទទួលរងអំពើហិង្សាទាំងផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទ ។ មកដល់ពេលនេះ អ្នកស្រុកអ្នកភូមិ និងកូនៗរបស់គាត់ដឹងថាប្តីប្រពន្ធគាត់ជាប្តីប្រពន្ធដែលត្រូវបានខ្មែរក្រហមបង្ខំឲ្យរៀបការដោយគាត់និយាយក្រាប់គេដោយផ្ទាល់មាត់ ។ ពួកគេមានប្រតិកម្ម ធម្មតានៅពេលដែលបានឮរឿងនេះ ប៉ុន្តែមានអ្នកខ្លះបាននិយាយថា ប្រសិនបើជាគេវិញគ្មានអ្នកណាហ៊ានបង្ខំទេ ។ ទំនាក់ទំនងរបស់គាត់នឹងប្តីស្ទើរតែផ្តាច់ឈានដល់ការលែងលះគ្នា ប៉ុន្តែគាត់មិនអាចធ្វើទៅបានដោយសារតែគិតដល់កូនៗ មិនចង់ឲ្យជនទុទៅមាក់ងាយថាជាកូនគ្មានឪពុក ។ ពើរោះជាមានការពន្យល់ពីផលប៉ះពាល់នានាពីការរស់នៅក្រោមអំពើហិង្សា និងជួយក្រោមជ្រែងលើកទឹកចិត្តពីសមាជិកក្រុមជួយខ្លួនឯង កំដោយកំគាត់មិនអាចដើរចេញពីចំណងនេះបានដែរដោយសារតែខ្វល់ខ្វាយច្រើនពីកូនចៅ ។

ចាប់តាំងពីសង្គ្រាមចប់មក អ្នកស្រីបានបង្កើតគ្រួសារនេះឡើងដោយដៃទាំងពីរផ្ទាល់របស់គាត់ គាត់ខំប្រឹងធ្វើស្រែលើដីដែលមានតិចតួច ស៊ីឈ្នួលគេដកស្ទូងបន្ថែមទៀត ដើម្បីរកគ្រាក់បន្ថែម ដើម្បីជួយទប់ទល់ការចិញ្ចឹមកូនទាំង៧នាក់ ។ ប្តីរបស់គាត់មិនសូវបានជួយរកគ្រាក់ចិញ្ចឹមគ្រួសារទេ គាត់រកគ្រាក់បានបន្តិចបន្តួចម្តងម្កាល ពីរបរស៊ីឈ្នួលរំកិលដីរបស់គាត់ ប៉ុន្តែគឺគ្រាន់តែសម្រាប់គាត់ចាយវាយផ្ទាល់ខ្លួនតែប៉ុណ្ណោះ ។ ការលំបាកពីការខំប្រឹងប្រែងធ្វើការរកគ្រាក់ដើម្បីចិញ្ចឹមកូនមិនចោទជាបញ្ហាធ្ងន់ធ្ងរប៉ុន្មានសម្រាប់អ្នកស្រីនោះទេ ប៉ុន្តែអ្វីដែលលំបាកធ្ងន់ធ្ងរបំផុតនោះគឺអំពើហិង្សាផ្លូវភេទដែលបានទទួលពីប្តី ។ ចាប់តាំងពីឆ្នាំ ២០០០មក ប្តីរបស់គាត់តើតជាការប្រច័ណ្ឌចោទប្រកាន់ថាអ្នកស្រីមានសាហាយបង្ខូចមេទជាប្រចាំដោយមិនយោគយល់ ថាអ្នកស្រីឈឺឬជាអ្វីឡើយ ។ ប្តីរបស់អ្នកស្រីមានបញ្ហាអាកប្បកិរិយាផ្លូវភេទចម្លែក ដោយមានតម្រូវការខ្ពស់ មិនយោគយល់ ភាន់ច័ន្ទិត និងវង្វេងញាណថា មានសាហាយលបលួចហែកជញ្ជាំងមករក

ប្រពន្ធរបស់គាត់ ។ ដោយសារតែការកាន់នៃញាណបែបនេះធ្វើឲ្យគាត់កាន់តែមានការប្រចំណ្ឌ និងបង្កើនតម្រូវការផ្លូវភេទកាន់តែ ច្រើនទៀត ។ អ្នកស្រីយល់ថាសង្ត្រាម ក្នុងនោះមានការបង្ខំឲ្យរៀបការជងនោះធ្វើឲ្យប៉ះពាល់ដល់ជីវិតរបស់គាត់យ៉ាងខ្លាំង ជាពិសេសប៉ះ ពាល់ផ្លូវចិត្ត (ពិបាកចិត្ត ឈឺចិត្ត) ទទួលរងអំពើហិង្សាផ្លូវភេទធ្ងន់ធ្ងរជីវភាពគ្រួសារក្រលំបាកដោយសារតែប្តីមិនខិតខំប្រឹងប្រែងរកស៊ី ធ្វើការទេ ប៉ុន្តែបែរ ជាបង្ករបញ្ហាឲ្យគាត់ថែមទៀត ។

អ្នកស្រី ហេង គុយឡាង យល់ថាក្រុមជួយខ្លួនឯងរបស់អ្នកស្រីជាក្រុមមួយដែលចេះស្រឡាញ់គ្នា ជួយគ្នាបានច្រើន មានភាពសប្បាយ រីករាយច្រើន ហើយសកម្មភាពនានាពីក្រុមនេះបានធ្វើឲ្យគាត់បានយល់ដឹងច្រើនពីវិធីរម្ងាប់អារម្មណ៍ បានទទួលដំណោះស្រាយល្អៗ ពីក្រុម និងបានទទួលភាពកក់ក្តៅពីក្រុមបើទោះជាទើបតែជួបគ្នាមួយរយៈពេលខ្លី ។ គាត់ចូលចិត្តសកម្មភាពមួយចំនួនជួចជាការធ្វើសមាធិ បន្ទូរអារម្មណ៍ពីការតានតឹងចិត្ត វិធីសាស្ត្រអនុវត្តការដោះស្រាយបញ្ហាជាក្រុមដោយប្រើស្ថានក្រដាស វិធីសាស្ត្រកសាងទំនុកចិត្ត ដោយឲ្យធ្វើការជាគូ ម្នាក់ជាអ្នកបើកបរ ម្នាក់ជារថយន្ត (the blind car) ការគូររូបផ្សេងៗអំពីភាពខ្លាំងរបស់យើងម្នាក់ៗ ការគូររូបស្ទឹងជីវិតដើម្បីឆ្លុះបញ្ចាំងពីជីវិតរបស់យើងទាំងមូល និងការពួនឱ្យាច់ ។

អ្នកស្រីគិតថានឹងនៅតែបន្តជួប និងជួយគាំទ្រក្រុមរបស់អ្នកស្រី បន្ត ទៀត បើទោះបីជាអ្នកស្រីនៅឆ្ងាយពីគេជាងគេតែម្នាក់ឯងក៏ដោយពីព្រោះអ្នកស្រីមិនចង់នៅឯកោតែម្នាក់ឯងទៀតទេ ត្រូវតែខំពង្រឹងខ្លួនឯង និងបន្តផ្តល់កម្លាំងចិត្តដល់សមាជិកក្រុមវិញ ដូចដែលពួកគេផ្តល់ឲ្យគាត់ដែរ ។ អ្នកស្រីយល់ថាការចងក្រងជាក្រុមរវាងអ្នកដែលមានបទពិសោធន៍ឈឺចាប់ដូចគ្នាបែបនេះ ពិតជាមានប្រយោជន៍ណាស់ ពីព្រោះពួកគាត់អាចចែករំលែក ជាពិសេសស្គាល់ពីទុក្ខលំបាកគ្នាទៅវិញទៅមក ។

ដើមឈើ ហេង គុយឡាង

The Tree

អ្នកស្រីយល់ថាពិតជាមានការខុសប្លែកពីមុន និងក្រោយការចូលរួមជាមួយក្រុមជួយខ្លួនឯងនេះ ។ អ្នកស្រីមានប្រសាសន៍ ថាពីមុន អ្នកស្រី តែងតែយល់ថាខ្លួនឯងដូចជាស្លឹកឈើទុំជ្រុះខ្យល់បក់ប៉ើងទៅគ្រប់ទិសទីជាកន្លែងដែលគ្មានកោះត្រើយ ។ ពីមុនអ្នកស្រី មិនហ៉ាន និយាយស្តី អ្វីទាំងអស់ ប៉ុន្តែឥឡូវគិតថាខ្លួនឯងអស្ចារ្យណាស់ព្រោះបានយល់ដឹងច្រើនពីតុលាការខ្មែរក្រហម ហើយបានចូលរួមញឹកញាប់ គាត់ក៏បាន យល់ដឹង និងអាចទទួលយកអ្វីដែលបានកើតឡើងកន្លងមក ចេះអត់ឱននិងចេះជួយគ្នា ប៉ុន្តែគាត់នៅតែមានអារម្មណ៍ឯកោខ្លះៗដែរ ព្រោះនឹង ត្រូវបែកពីក្រុម នឹងមិនសូវបានជួបមុខគ្នារៀងរាល់ខែដូច្នេះទៀតទេ ។ អ្នកស្រីមានពាក្យពេចន៍ ជ្នាំផ្ទើរទៅកាន់មនុស្សគ្រប់រូបថាសូមឲ្យពួកគាត់ចងចាំរៀងនេះទុកជាប្រវត្តិសាស្ត្រជាពិសេសសម្រាប់មនុស្សជំនាន់ក្រោយៗទៀត ហើយ គាត់សូមសំណូមពរអ្នកជំនាន់ក្រោយៗធ្វើយ៉ាងណាដើម្បីកុំឲ្យមានរបបនោះកើតមានទៀត ។ អ្នកស្រីយល់ថាជីវិតរបស់គាត់សព្វថ្ងៃ មានការពិបាកតានតឹងចិត្តច្រើនលើជីវភាព និងការរស់នៅក្នុងគ្រួសារ ធ្វើស្រែមិនបានដោយម្តង ទឹកជំនន់ ម្តងរាំងស្ងួត ប៉ុន្តែគាត់មិន ចង់ធ្វើចំណាកស្រុកទៅរកស៊ីឆ្ងាយចោលកូនចៅទេ ។ គាត់គិតថាទៅថ្ងៃអនាគតគាត់នឹងនៅតែប្រឹងប្រែងបន្តរស់ថែរក្សាកូនឲ្យពួកគេ រៀបការ មានគ្រួសារត្រឹមត្រូវចប់អស់ បើទោះជាត្រូវអត់ធ្មត់ ធ្វើមិនដឹងមិនឲ្ប មិនប្រឆាំងតវ៉ាចំពោះរាល់បញ្ហាដែលកើតមានក្នុងផ្ទះ ជាពិសេសរឿងវាវដែលមានជាមួយប្តីរបស់គាត់ក៏ដោយ ។

Ms. HENG Kuylang

Ms. HENG Kuylang, 57, lives in Os Tuok village, Kampong Preang commune, Sangke district, Battambang province. Ms. Kuylang has seven children, four girls and three boys. She makes a living by growing crops, and also works as an assistant cook for a mobile food supplier team.

Before the Khmer Rouge (KR)era, she worked as a maid for a family in Toul Svay Prey, Phnom Penh. When the KR came to power she was evacuated to Doung village, Takeo province and was forced to work producing crops and digging canals. She was later evacuated again to Mouk Kampol district, Kandal province. After only six months, she was again forced to move to Battambang province.

In 1977, around 9:00 am, she was forced to marry a man she didn't know, together with two other couples. Despite the forced circumstances of their marriage, she and her husband are still together to this day. The relationship with her husband is not good and they do not love each other. They married only in order to stay alive. They raised children together but still they did not love each other. Ms. Kuylang is an orphan therefore doesn't have relatives who she can seek support from, if she ever decides to leave her husband. The biggest reason she feels unable to break up with her husband is the children. Ms. Kuylang endures suffering from abuse of a mental, physical and sexual nature. She told everyone in the village, including the children that she and her husband were joined by the KR, and not properly married as a result of love and through a parental arrangement. People seemed to not be surprised hearing this. Others thought that if they had been in the position of Ms. Kuylang they wouldn't have allowed the forced marriage to happen.

Their marriage, at one point,nearly ended. She couldn't do it because she did not want others to look down on her children as the children of a single mother. She was supported emotionally by members of her self-help group who explained the impact and effect of living in a domestically violent relationship. Despite their encouragement, Ms. Kuylang could not make radical decision to leave her husband.

Ms. Kuylang indicated that ever since the war ended, she has supported her family with her bare hands. She worked extra hard– producing crops on her small piece of land and worked for others to feed her seven children. Her husband did not help by bringing in as much income. He also sometimes worked for other people but kept his earnings for himself as pocket money. Working hard to feed seven children is not something to complain, explained Ms. Kuylang. The greatest suffering has come from the sexual violence she has experienced at the hands of her husband.

As of 2000, Ms. Kuylang's husband has becoming increasingly consumed by jealousy, as he suffers from the delusion that his wife is seeing another man. He constantly accuses her of betraying him, committing adultery and forces her to have sexual intercourse with him every day, even if she's not well.

Ms. Kuylang thinks forming a group of people who share similar experiences like this is good and helpful because they can share their painful memory and other difficulties in life with each other in a comfortable and safe space.

Her husband, according to Ms. Kuylang, has strange sexual habits. He has a high sex drive, and demands sex. He also suffers from hallucinations in which he sees his wife's lover come through the wall to have sex with his wife in front of him. In the recent past, his hallucination were so vivid that he became furious. He pulled out a chopping knife and attacked her. Luckily, Ms. Kuylang turned away and avoided the blows. She then escaped to a safe place. (This sex maniac might be the cause of the hallucinations or the hallucinations might be the cause of the sex.) Sadly, the poor woman has had to put up with her husband's sexually manic behavior for years. Ms. Kuylang said the war, including her forced marriage, has had a huge impact on her life, especially her mental health (she feels constant emotional pain), she suffers from severe sexual violence, and the family finances are lean because her husband makes no effort to earn money but rather makes her life more difficult.

Ms. Kuylang thinks that her self-help group is one that loves each other and is helpful; so that all group members can be happier. Moreover, the group activities also made her more knowledgeable in terms of how to calm down. She also received positive solutions from the group despite the fact they normally just meet once a month and for a short time. She liked some group activities such as the meditation and the breathing exercises which helped to reduce her level of stress, group methods to deal with problems in the course of team work, trust building exercises like the blind car and others, the drawing and painting of our own resources and strength, drawing the river of life to reflect her whole life path, and closing the suffering with the sand.

Ms. Kuylang thinks that she will continue to meet with, and support the team members, despite being the only one in the team who lives far away from the others, because she doesn't want to be as lonely as she was before. She said she has to strengthen herself and support her team members as they support her. She thinks forming a group of people who share similar experiences like this is good and helpful because they can share their painful memory and other difficulties in life with each other in a comfortable and safe space.

Ms. Kuylang sees herself differently since joining the group. She said that before she joined the group she thought she was an old leaf from a tree that fell off and flew away alone in the wind to somewhere that is far from people's reach. She was a person who spoke very little. But now she feels like she is a great person because she feels supported, knows more about the court and its processes, and, in particular, she is more knowledgeable and accepting of the past, is able to forgive and is becoming a more helpful person. However, she still feels a bit lonely because the group meetings which were facilitated by the CDP are finished and as a result she will not meet her fellow group members as regularly as she did before.

Ms. Kuylang wants to tell the public, in particular the younger generations to please keep the sufferings of the Cambodian people who lived through the KR regime on the historical record in order to help ensure a regime like that never comes to power again.

Ms. Kuylang thinks that her current life is one of difficulty, which involves much stress about family finances and daily living because she can't tend to her rice fields. Last year they suffered from flooding, this year they suffer from drought, another year they suffered from the rice becoming diseased etc. However, despite this she still will not leave the country to find work elsewhere. She thinks that she is going to love and take care of herself more and help her children raise their families and look after her grandchildren. She also hopes to be more patient with her husband and learn to ignore some of the troubles he causes.

Ms. HENG Kuylang

អំ ង៉ុន

អ្នកស្រី អ៊ំ ងុន អាយុ ៥៤ឆ្នាំ ជាកសិកររស់នៅភូមិគំពង់ក្តី ឃុំរំលេច ស្រុកបាកាន ខេត្តពោធិសាត់ ។ អ្នកស្រីមានកូន ៨នាក់ ប្រុស៥នាក់ ស្រី៣នាក់ ដែលកូនប្រុសពៅរបស់អ្នកស្រីមានជម្ងឺប្រកាច់វ៉ាំរ៉ៃ ដោយមិនដឹងមូលហេតុច្បាស់លាស់។ កាលពីមុនសម័យខ្មែរក្រហមអ្នកស្រីរស់នៅភូមិស្អកខ្ពុំ ឃុំបាក់ចិញ្ចៀន ស្រុកក្រវ៉ាញ ខេត្តពោធិសាត់។

កាលពីឆ្នាំ ១៩៧៣ អ្នកស្រីមានអាយុ ១៣ឆ្នាំ នៅរៀនថ្នាក់ទី២ ប៉ុន្តែដល់អាយុបាន ១៥ឆ្នាំ គាត់ត្រូវបានគេឲ្យឈប់រៀនជម្លៀស មកនៅភូមិស្អកខ្លា ដោយឲ្យគាត់បង្រៀន ក្មេងតូចៗដែលមាន ចាប់ពីអាយុ ៤ឆ្នាំ ដល់ ១០ឆ្នាំ ហើយជម្លៀស ពីកន្លែងមួយទៅ កន្លែងមួយទៀតជាច្រើនដង ។ តំបន់ដែលគាត់រស់នៅមាន ខ្មែរក្រហម តាំងពីមុន ឆ្នាំ ១៩៧៥ ពេលដែលខ្មែរក្រហមឡើង កាន់អំណាចទៅទៀត ។

នៅឆ្នាំ១៩៧៤ ខ្មែរក្រហមបានជម្លៀសគាត់ឲ្យមកនៅ ភូមិសំរោង ឃុំបាក់ចិញ្ចៀន ។ នៅខែសីហា ឆ្នាំ ១៩៧៥ ម៉ោងប្រហែលជា ១០ព្រឹក នៅវត្តស្នួង អ្នកស្រីត្រូវបាន ខ្មែរក្រហមបង្ខំឲ្យរៀប ផ្ទួសារក្នុងវ័យ ១៧ឆ្នាំ។ នៅ ពេលនោះមិនស្គាល់ជាតឹងតែងខ្លាំង ពេកនៅឡើយទេ ការរៀបការគឺមានតែមួយគូប៉ុណ្ណោះក្នុងមួយថ្ងៃ ប៉ុន្តែគាត់ក៏មិនបានដឹងថាខ្លួននឹងរៀបការជាមួយអ្នកណានោះទេ គឺ ស្តាប់តាមបញ្ជាគេទាំងអស់ ។ យប់ថ្ងៃរៀបការមានឈ្លបតាមដាន ប៉ុន្តែគាត់អាចរួចខ្លួនរហូតបាន៣យប់ដោយមិនត្រូវបានប្តីចាប់បង្ខំទេ ។ ខ្មែរក្រហមបានដឹងពីការមិនព្រមរួមដំណេកនឹងគ្នា ក៏បានហៅអ្នកស្រី និងប្តីមកព្រមានកសាង ទើបធ្វើឲ្យ គាត់យល់ព្រមរួមដំណេក ។ ប្តីរបស់ គាត់ជាមនុស្ស ស្លូតបូតមិនចេះវាយតប់ ឬតវ៉ាអ្វីទេ ។ ដល់ចុង ឆ្នាំ ១៩៧៥ អ្នកស្រី និងប្តីត្រូវបានខ្មែរក្រហមជម្លៀសឲ្យមករស់នៅ ភូមិស្វាយដូនកែវធ្វើការក្នុងកងនារីដាំបាយកាប់ឆ្ការព្រៃធ្វើចំការ អាស្រ័យ តែនឹងគេរៀប ចំផ្លាស់ប្តូរឲ្យ ។ អ្នកស្រីមានកូនម្នាក់ជាមួយ ប្តីដែលបង្ខំឲ្យរៀបការនោះ ប៉ុន្តែនៅពេលដែលគាត់ សម្រាលកូន២ខែ ប្រហែលជានៅខែឧសភា ឬ ខែមិថុនា ឆ្នាំ១៩៧៧ ខ្មែរក្រហមបាន យកប្តីអ្នកស្រី ទៅសម្លាប់ដោយគាត់មិនដឹងមូលហេតុអ្វីសោះ ហើយ ក៏មិនហ៊ានសួរដែរ ។ ពេលនោះក៏មានស្ត្រី ៤នាក់ ទៀតដែរដែលត្រូវ គេយកប្តីទៅសម្លាប់ជា មួយគ្នានោះ ប៉ុន្តែពួកគាត់មិនមាននរណាម្នាក់ ហ៊ានសួរគ្នាទេព្រោះខ្លាចខ្មែរក្រហមយកទៅសម្លាប់ ។ អ្នកស្រុក និង កូនៗរបស់អ្នកស្រីសុទ្ធតែបានដឹងរឿង ការបង្ខំឲ្យរៀបការរបស់គាត់ ពួកគេបង្ហាញការយល់ចិត្តដោយយល់ថាវាជារឿងទូទៅធម្មតាទៅ ហើយកាលពីម័យនោះ ។

អ្នកស្រីបានរៀបការម្តងទៀតក្នុងឆ្នាំ ១៩៨០ ក្នុង នាមជាស្ត្រីមេម៉ាយ កូនមួយជាមួយបុរសពោះម៉ាយ ដែលធ្លាប់បានខ្មែរក្រហមបង្ខំឲ្យរៀប ការដែរ ។ ទំនាក់ទំនងរបស់អ្នកស្រីនឹងស្វាមីថ្មីនឹងគ្នាធម្មតាមានពេល ខ្លះក៏ឈ្លោះទាស់សម្តីគ្នាដែរ ប៉ុន្តែមិនដែលវាយដំគ្នានោះទេ ។ តាំងពី ដើមមកគាត់ហូបស្រាម្តងម្កាលពេលជួបជុំមិត្តភក្តិ ប៉ុន្តែឥឡូវនេះគាត់ ហូបបន្តិចៗរាល់ថ្ងៃ ព្រោះកូនស្រីបើកលក់របរនេះនៅផ្ទះ ហើយធ្វើឲ្យ អ្នកស្រីមានការធុញទ្រាន់ជាខ្លាំងព្រោះពេលគាត់ស្រវឹងម្តងៗ គាត់ ឡូឡាដាក់ប្រពន្ធកូន ។ អ្នកស្រី និងប្តីមានទំនាក់ទំនងល្អជាមួយនឹង កូនៗទាំងអស់ មិនដែលគិតថាកូនមុន ឬកូនក្រោយអ្វីនោះទេ គឺពួក គាត់ស្រឡាញ់ដូចៗគ្នា ។

ចាប់តាំងពីសង្ត្រាមបានបញ្ចប់មកអ្នកស្រីមិនមានរបរអ្វីក្រៅតែពីការធ្វើស្រែចំការនោះទេ ។ បន្ទុកការងារ និងការចិញ្ចឹមបីបាច់ថែរក្សាកូនទាំងអស់ស្ថិតនៅលើអ្នកស្រីជាអ្នកភប់រង ប្តីរបស់គាត់ជាទាហ៉ានដើរបាត់ៗពីផ្ទះ ។ គាត់ភប់រងទាំងអស់ទាំងការងារ មនុស្សប្រុស និងការងារ មនុស្សស្រី ដូចជាភ្ជួរ ភស់ ដក ស្ទូង ចំណីអាហារ កូនរៀន ។ល។ ប្រាក់ខែទាហ៉ានរបស់ប្តីមានតិចតួចមិនទាំងគ្រប់គ្រាន់ថ្លៃធ្វើដំណើរបស់ប្តី គាត់ទៅមកពីបន្ទាយ មកផ្ទះម្តងម្កាលនោះផង តែផ្ទុយទៅវិញគឺមានតែយកលុយផ្ទះគ្រឡប់ ទៅវិញ ។ គាត់យល់ថាសង្ត្រាមពិតជាធ្វើឲ្យប៉ះ ពាល់ដល់ជីវិតគាត់យ៉ាងខ្លាំង ធ្វើឲ្យគាត់រៀបការប្តីដល់ទៅពីរដង មិនបានរស់នៅ ជុំប្តីដោយសារតែរវល់តែទៅធ្វើទាហ៉ាន នាំឲ្យប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារ កូនមិនបានរៀនសូត្រខ្ពង់ខ្ពស់ ។

ពីមុនអ្នកស្រីមិនស្គាល់សមាជិកក្នុងក្រុមជួយខ្លួនឯងទាំង៨នាក់នេះទេ ប៉ុន្តែតឡូវគាត់មានអារម្មណ៍ថាទំនាក់ទំនងរបស់ពួកគាត់ដូចជាបងប្អូន និងគ្នាពួកគាត់មានទំនាក់ទំនងល្អស្មោះត្រង់ ជឿជាក់ យល់ចិត្ត យល់សុខទុក្ខគ្នាណាស់ ។ ចំពោះក្រុម និងសកម្មភាពនានា ដែលបានធ្វើនៅ ក្នុងក្រុមធ្វើឲ្យគាត់មានអារម្មណ៍ថាបានធូរស្រាលរសាយចិត្តមួយចំណែកធំ មេរៀននិងការសម្របសម្រួលក៏បានធ្វើឲ្យគាត់យល់ដឹងច្រើនជាងមុន ។ សកម្មភាពដែលគាត់ចូលចិត្តគឺការធូររូប បើទោះជាគាត់មិនសូវចេះ ហើយមិនដែលបានធ្វើភពីមុនក៏គាត់ចូលចិត្ត ហើយការដើរកំសាន្តខ្លះ ៗ ក្នុងទីក្រុងក៏ធ្វើឲ្យគាត់សប្បាយរីកភយដែរ និងពិធីបិទជំនួបដោយប្រើខ្សាច់ ថ្ម ផ្តា ។ល។ ក៏ធ្វើឲ្យគាត់សប្បាយនិងអាចទទួល យកអតីតកាលរបស់ខ្លួនដោយអស់ចិត្តដែរ ។ អ្នកស្រីមានប្រសាសន៍ថា គាត់មិនដែលមានពេលសប្បាយ លេង សើច ដូចជាពេលជំនួបក្រុមម្តង ៗនោះទេ ព្រោះពួកគាត់គិតតែពីធ្វើអ្វីៗគ្រប់យ៉ាងដើម្បីសេដ្ឋកិច្ចគ្រួសារ ប៉ុណ្ណោះ ។ អ្នកស្រីនឹងនៅតែបន្តជួយគាំទ្រក្រុមមួយនេះ តទៅទៀត ដោយនៅតែខុសឃ្យាហ៍ទូរស័ព្ទរកគ្នា មកលេងគ្នាឲ្យបានញឹកញាប់តាមដែលអាចធ្វើទៅបាន ។

អ្នកស្រីយល់ថាខ្លួនគាត់ខុសពីមុនពេលដែលបានចូលរួមចងក្រងក្រុមនេះ ដោយពីមុនគាត់មិនសូវនិយាយទេ ជាពិសេសចូលចិត្តលាក់រឿង ពិបាកចិត្តលាក់អារម្មណ៍មិនឲ្យគេដឹង ប៉ុន្តែតឡូវគាត់អាចនិយាយចេញឲ្យធូរចិត្តបានសប្បាយចិត្តជាងមុន ទំនាក់ទំនងក្នុងគ្រួសារទាំងមូលប្រសើជាងមុន ជីវភាពក៏បានប្រសើរជាងមុន ជាពិសេសគឺគាត់មានអារម្មណ៍ថាកូន ៗរបស់គាត់គោរពស្រឡាញ់គាត់ជាងមុន ។

អ្នកស្រីមាន ពាក្យពេចន៍ផ្តាំផ្លើរទៅកាន់ជនរងគ្រោះពីការបង្ខំឲ្យរៀបការ និងការរំលោភផ្លូវភេទដទៃទៀតថា រូបគាត់ក៏ជួបបញ្ហាដូចគ្នារវញ្ចឹងដែរ សូម ក្លាហានក្រោកឈរឡើងកុំលាក់រឿងឈឺចាប់ហ្នឹងតែម្នាក់ឯងតទៅទៀត ចងក្រងជាក្រុមដូចពួកគាត់ ហើយស៊ុសំណូមពរឲ្យអង្គការជួយគាំទ្រគាត់ ដូចជាជួយគាំទ្រក្រុមរបស់អ្នកស្រីដែរ ។

អ្នកស្រីយល់ថាជីវិតរបស់គាត់ស៊ាំនឹងការលំបាកទៅហើយ មានកូនច្រើនត្រូវប្រឹងប្រែងធ្វើការដើម្បីចិញ្ចឹមកូន ប៉ុន្តែគាត់ពេញចិត្ត និងជីវិតរបស់ខ្លួនទោះជាបានជួបការលំបាកទាំងអស់នេះក៏ដោយ ។ អ្នកស្រីគិតថាទៅអនាគតគាត់នឹងនៅតែបន្តជួយគាំទ្រកូន ៗ មើលឃើញគេមានគ្រួសារអស់ជួយមើលថៅ ៗ និងទៅវត្តដើម្បីសន្សំបុណ្យកុសល ។

Ms. OM Ngon

Ms. OM Ngon, 54, is a peasant who lives in Kompong Kdei village, Romlech commune, Bakan district, Pursat province. She has five sons and three daughters. Her youngest son suffers from epilepsy which causes him to have regular fits. Because of this, she must always be with him, and spends lots of money on his treatment.

Before the KR era she lived in Sdok Ktom village, Bak Chechean commune, Kravanh district, Pursat province. The region she lived in was occupied by Khmer Rouge (KR) soldiers before they captured the whole country in 1975.

In 1973 she was 13 and attended grade 2 at school. However, she was forced to stop school at age 15 because of the evacuation. When this occurred, she was initially evacuated to Sdoc Khla village where she was assigned to teach children aged between 4 to 10, and was later was evacuated to a few other places.

In 1974 she was evacuated by the KR to live in Samronge village, Bak Chechean commune. One morning in August 1975 at about 10 am, she was forced to get married. She was 17 years old. That year, the conditions governing forced marriages were not so strict; only one couple was married at a time, but like the experience of others, she did not know her husband before she was married to him. She and her husband were assigned to be married by Angkar.

As was the experience of other forced marriage couples, she and her husband were watched by KR cadre on their wedding night. Luckily she was able to avoid being forced to consummate her union for the first three nights of her marriage. However by the forth night she could avoid it no longer; the KR knew their marriage had not been consummated and issued a warning to the couple and forced her to agree to have sex with her husband.

Ms. Ngon's husband was a good and gentle man; he never beat her or agued with her. In 1975 she and her husband were again forced to evacuate to Svay Daunkeo, where she was required to work in the women's mobile group. The tasks assigned to this group were always changing according to the directions given by Angkar, but included cooking and clearing the land for crops and rice fields etc. Ms. Ngon had one daughter with her husband through forced marriage. When her daughter was two months old in around May or June 1977, the KR took her husband away to be killed for no reason. There were four other ment aken to be killed with her husband. Ms. Ngon and the wives of the other four men did not dare ask any questions because they were afraid that theywould be taken away to be killed like their husbands

The villagers and her children knew about her forced marriage and they showed empathy to her and said it was normal at that time because nearly everyone experienced forced marriage.

Ms. Ngon remarried in 1980 to a widower who was also previously in a forced marriage. The relationship between her and her second husband is good; although they sometimes quarrel, he has never beaten her. When they first married he would occasionally drink wine with friends or neighbors but now he drinks a little bit every day because their children opened a small grocery at home. Although he only drinks a little, it makes her uncomfortable as he sometimes gets drunk and shouts at her and the children and complains. She and her husband treat all the children equally. They never distinguish them as the children from the first or second marriage.

When the war ended she worked in the rice fields to support the family. She had sole responsibility for the family (including earning an income and caring for the children)as her second husband was a soldier who lived at the military base far from home. She did the work of a man and a woman, such as ploughing, planting crops and seedlings, cooking for the children, schooling the children etc. The salary that her husband got from the army was not enough to even cover his travel costs for a visit home from the military base instead he took some money from home back to work.

Ms. Ngon feels that the war had a huge impact on her life. She was married twice; her first husband was killed; and her second husband was away from the family, busy fighting, which made make the family finances very tight, and her children were not able to attend school because they had to help their mother earn a living.

Painting of resources she does to cope with daily life stress

Before joining the self-help group, Ms. Ngon did not know any members of the team, but now she feels like their relationship with each other is like that of sisters. Their relationship is good, trusting, empathetic, and helpful. Team spirit and other activities facilitated by the group help her to feel a big sense of relief. In particular, she feels that she has learned a lot from the facilitation process. The activities that she liked the most include drawing and painting (though she did not know how to do either activity as she had never done them before), the tour of the city, and the closing ritual using sand to play etc. She says these activities made her happy and feel acceptance of her past. She said she has never had time to get out of the house to have fun, laugh and be happy like she did at the meetings because all she, and every other group member had ever thought about and did was for the sake of the family, to the extent that they forgot to think about their health. She said she will still continue to support this team by making the time for the group members to meet with each other or at least call each other as much as they can.

Ms. Ngon feels she is different since joining the group. Prior to joining the group, she describes herself as a person who did not speak much and liked to keep things to herself and did not let others know her thoughts. Now she has the confidence to speak out in order to release her stress and tension. Because of this, she feels happier, her relationship with and between family members is better, and her family economy is improving. In particular, she feels that her children love her more than ever before.

Ms. Ngon would like other victims of forced marriage and sexual abuse to feed that they are not alone, that she shares their experiences. She wants to tell them to be strong and not to try and hide their painful truth; stand strong and form a group like hers. She also suggests that they seek support from CDP and other civil society organizations like she her and her group did.

Ms. Ngon thinks she has lived a resilient life in which she has had to adapt to the difficulties; including working and raising many children alone etc.; but despite the difficulties she has experienced, she is satisfied with her life. In the future she still wants to continue to support her children until they are all married. When this happens, she wants to help to look after her grandchildren and to go to the pagoda more regularly.

អ៉ឹ យ៉ាន

អ្នកស្រី អ៉ឹ យ៉ាន អាយុ៥៦ឆ្នាំ រស់នៅភូមិខ្នារទទឹង ឃុំខ្នារទទឹង ស្រុកបាកាន ខេត្តពោធិសាត់ ។ អ្នកស្រីជាកសិករ មានកូន ៧នាក់ កូនស្រីម្នាក់ បានទៅធ្វើការនៅប្រទេសម៉ាឡេស៊ីតាំងពី អាយុ១៥ឆ្នាំ កូនប្រុសម្នាក់ទៅប្រទេសថៃ កូន៤នាក់ទៀត មានគ្រួសារហើយបានទៅរកស៊ីធ្វើកម្មករនៅប្រទេសថៃម្តងម្តាលដែរ ដោយសារតែបញ្ហាជីវភាព ព្រោះតែធ្វើស្រែចំការមិនបាន មួយឆ្នាំភ៉ាង មួយឆ្នាំទឹកជំនន់ ឆ្នាំខ្លះស្រូវមានជម្ងឺ ។ សព្វថ្ងៃអ្នកស្រីរស់នៅជាមួយស្វាមី កូនប្រុសពៅម្នាក់នៅរៀន និងចៅ៦៣នាក់ទៀតដែល ឌីពុកម្តាយគេផ្ញើរឲ្យនៅជាមួយជីដូនពេលពួកគេចេញទៅប្រទេសថៃ។

មុនសម័យខ្មែរក្រហម គាត់រស់នៅភូមិគោកឌ៉ឡឹក ឃុំស្តានថ្ម ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ធ្វើស្រែចំការ និង មើលថែទាំប្តូនៗ ។ នៅចុងឆ្នាំ១៩៧៣ ដោយមានការទម្លាក់គ្រាប់បែកយ៉ាងច្រើនសន្ធឹកសន្ធាប់ គាត់ពេលនោះអាយុទើប តែ១២ឆ្នាំ បានរត់ចេញពីភូមិជាមួយម្តាយមីង ជីដូន និងអ្នកភូមិផ្សេងទៀត នៅពេលដែលបានឲ្យថាទាហ៉ានខ្មែរក្រហម ជិតចូលមកដល់ភូមិរបស់គាត់ហើយ ។ ពេលរត់តាមផ្លូវពួកគាត់ទាំងអស់បានជួបជាមួយក្រុមទាហ៉ាន លុន ណុល ហើយបានជួយនាំមកស្នាក់នៅក្នុងម្ពុំជ្ជល់បត់ចំការដូង ក្នុងបំណងគេចពី ប៉ុល ពត ។ រស់នៅទីនោះ បាន១ឆ្នាំចិញ្ចឹមជីវិតដោយ ការដើរបេះបន្លែយកមកឲ្យយាយលក់ដើម្បីទិញម្ហូបអាហារ ។ អ្នកស្រីបានបែកពីឌីពុក និងម្តាយចុងតាំងពីពេលនោះមក រហូតដល់ឥឡូវ មិនដឹងថាគាត់ស្លាប់ឬនៅរស់ ព្រោះពេលរត់ចេញពីភូមិនោះ ឌីពុករបស់គាត់មិននៅផ្ទះទេ គាត់បានទៅធ្វើការនៅឯចំការ ហើយខ្មែរក្រហមបានគៀងជម្លៀសគាត់មិនដឹងជាទៅណាទេ ។ ពេលខ្មែរក្រហមវាយបែកភ្នំពេញ ទើបគេ ជម្លៀសអ្នកស្រីម្តាយមីង ជីដូន និងប្តូនៗ មកស្រុក បាកាន ខេត្តពោធិសាត់ ។ គាត់ត្រូវបានខ្មែរក្រហមចាត់ឲ្យធ្វើការនៅកងចល័តនារីធ្វើស្រែចំការដកស្ទូងលើកប្រឡាយ និងកាប់ព្រៃដោយ ធ្វើការងារយ៉ាងធ្ងន់ធ្ងរ ។ អ្នកស្រីត្រូវបានខ្មែរក្រហម បង្ខំឲ្យរៀបការក្នុងឆ្នាំ ១៩៧៧ មៀងប្រហែល ៧យប់នៅឯសាលា ឃុំខ្នារទទឹង បន្ទាប់ពីគាត់បាន ត្រឡប់មកពីធ្វើការងារកាប់ព្រៃ ។ អ្នកស្រីបានរៀបការ ជាមួយ នឹង ២៤ឆ្នូផ្សេងទៀត ហើយយប់ថ្ងៃរៀបការនោះ ក៏មានល្លូបតាមដានដូចការបង្ខំឲ្យរៀបការដទៃទៀតដែរ ។ ប្តីអ្នកស្រីបានចាប់បង្ខំអ្នកស្រីដោយ ប្រើកម្លាំងពេលនោះមានការប្រទូសសារាយនឹងគ្នា រហូតដល់បង្ខំបានសម្រេច ហើយក្រោយមកពួកគាត់ ក៏បានបន្តរស់នៅជាមួយគ្នារហូតដល់បច្ចុប្បន្ននេះ ។ មនុស្សភាគច្រើន ដែលនៅក្នុងភូមិស្រុកជា មួយ អ្នកស្រីសុទ្ធតែបានដឹងពីការបង្ខំឲ្យរៀបការនោះព្រោះ មានអ្នកខ្លះក៏បានបង្ខំក្នុងពេលជាមួយគ្នានោះដែរ

ឯ អ្នកខ្លះគ្រាន់តែ ៣ តៗគ្នា ឬអ្នកស្រីប្រាប់ដោយផ្ទាល់ ហើយមានតែមនុស្សចាស់មួយចំនួនទេដែលអាណិត អាសូរ និងលើកទឹកចិត្តគាត់ ប៉ុន្តែបងប្តូនសាច់ថ្លៃ របស់គាត់វិញមិនដែលឲ្យតម្លៃ និងទទួលស្គាល់គាត់ នោះទេរហូតដល់ពេលនេះ ។ ទោះជាអ្នកស្រីត្រូវបានខ្មែរក្រហម បង្ខំឲ្យរៀបការ ប៉ុន្តែប្តីប្រពន្ធគាត់នៅតែបន្តរស់នៅ ជាមួយគ្នារហូតដល់បច្ចុប្បន្ន បើទោះ ជាពេលខ្លះអ្នកស្រីមានអារម្មណ៍ថាគាត់រស់នៅ ដោយមានការពិបាកជាពិសេសសាច់ញាតិខាងប្តីរបស់គាត់មិនទទួលស្គាល់ និងមើលងាយគាត់ជាប្រចាំក៏ដោយ ។ នៅពេលដែលគាត់មានផ្ទៃពោះកូនទីមួយប្តីរបស់គាត់មានស្រីខាងក្រៅវៃប្រពន្ធ ដើរចោលផ្ទះ មិនយកចិត្តទុកដាក់នឹងប្រពន្ធប៉ុន្តែគាត់នៅតែទ្រាំមករហូត ។ អ្នកស្រីធ្លាប់បានព្យាយាមធ្វើបាបខ្លួនឯង និងប៉ុនប៉ងសម្លាប់ខ្លួនដោយលេបថ្នាំបំពុល ប៉ុន្តែត្រូវបានជួយសង្រ្គោះទាន់ពេល ។ អ្នកស្រីមានទំនាក់ទំនងល្អជាមួយនឹងកូនៗណាស់ គាត់ស្រឡាញ់កូនៗ ហើយកូនៗក៏ស្រឡាញ់គាត់ដែរ ប៉ុន្តែប្តីរបស់អ្នកស្រីមិនសូវមានទំនាក់ទំនងល្អជាមួយកូនៗប៉ុន្មាននោះទេ ។

ចាប់តាំងពីសង្រ្គាមចប់មកអ្នកស្រីចាប់ផ្តើមបង្កើតក្រុមត្រួសារទាំងបាតដៃទរទេរដោយប្រកបតែរបរធ្វើស្រែ ចិញ្ចឹមកូនតូចៗ ដោយមិនសូវបានឲ្យគេចូលរៀនបានត្រឹមត្រូវខ្ពង់ខ្ពស់នោះទេដោយសារតែបញ្ហាជីវភាព ។ សព្វថ្ងៃអ្នកស្រីមានជីវភាពមធ្យមដោយសារបានកូនៗ ដែលទៅរកស៊ីនៅក្រៅប្រទេសជួយខ្លះៗបន្ថែមលើចំណូលពីស្រែចំការរបស់គាត់ ។ អ្នកស្រី អ៊ំ យ៉ាន យល់ថាសង្រ្គាមបានធ្វើឲ្យគាត់បាត់បង់ច្រើនណាស់ ឪពុក បងប្អូន សាច់ញាតិ និងទ្រព្យសម្បត្តិទាំងអស់ ជាហេតុធ្វើឲ្យគាត់មានអារម្មណ៍ឯកោ ។ ទន្ទឹមនឹងនោះដែរការបង្ខំឲ្យរៀបការពីសំណាក់ទ្មែរក្រហមក៏ធ្វើឲ្យចិះពាល់ផ្លូវចិត្តអ្នកស្រីធ្ងន់ធ្ងរដែរដោយយល់ថាខ្លួនមិនសូវមានតម្លៃពុំមានការទទួលស្គាល់ពីសាច់ញាតិក្រុមគ្រួសារខាងប្តី ។ ពេលខ្លះអ្នកស្រីគិតចង់តែសម្លាប់ខ្លួន ប៉ុន្តែនៅបារម្ភពីកូនៗ ចៅៗ គិតវែងឆ្ងាយពីអនាគតរបស់ពួកគេ ។ តាំងពីបានចូលរួមក្រុមជួយខ្លួនឯងនេះមកអ្នកស្រីយល់ថាគាត់មានអារម្មណ៍ប្រុះស្រឡះជាងមុន សប្បាយចិត្តជាងមុនព្រោះបានសមាជិកក្រុម និងអ្នកសម្រុបសម្រួលជួយស្តាប់ដោយបង្ហាញការយល់ចិត្ត និងផ្តល់យោបល់ល្អៗ ។ ក្រុមបានជួយដោះស្រាយទុក្ខលំបាកឲ្យគ្រប់ៗគ្នាទាំងអស់ឲ្យបានធូរស្រាលមិនត្រឹមតែគាត់ម្នាក់នោះទេ ។ គាត់បានបន្ថែមថាក្រុម និងសកម្មភាពនានាពីការចូលរួមក្រុមនេះពិតជាបានចូលរួមចំណែកជួយព្យាបាលរបួសផ្លូវចិត្តរបស់គាត់បានដល់៧០ ទៅ ៨០ភាគរយ តាមរយៈការចែកវំលែកពីអតីតកាលដើម្បីបំភ្លចការឈឺចាប់នានា ។

អ្នកស្រីចូលចិត្តសកម្មភាពមួយចំនួនពីការសម្រុបសម្រួលក្រុមដូចជា ការគូររូបដើមឈើដែលតំណាងឲ្យខ្លួនឯង សាងសង់ក្ដីជ្ឋូរឪពុករបស់ គាត់តាមរយៈការប្រើដីខ្សាច់ និងលំបាត់នានាទៀត ដែលពាក់ព័ន្ធនឹងការដឹកនាំ និងការពឹងពាក់គ្នាក្នុងក្រុម ។ គាត់ នឹងនៅតែបន្តរាប់អានជួយគាំទ្រគ្នាបន្តទៀត ព្រោះដោយសារពួក គាត់ធ្លាប់បានជួបអនុស្សាវរីយ៍វេទនាដូចគ្នា ដូច្នេះនៅតែចង់ចែកវំលែក និងសួរសុខទុក្ខគ្នាទៅវិញ ទៅមកតាមរយៈការទៅរកគ្នា និយាយលេង ។ល។ អ្នកស្រីគិតថាការចងក្រងជាក្រុមរវាងមនុស្ស ដែលមានបទពិសោធន៍ស្រដៀងគ្នាបែបនេះគឺមានប្រយោជន៍ណាស់ គាត់មានភាពងាយស្រួលក្នុងការចែកវំលែក និងបំបាត់ការកើតទុក្ខបានពេលខ្លះដែរ ។ ពីមុនគាត់យល់ថាគាត់ជាមនុស្សម្នាក់ដែលតែងតែមានអារម្មណ៍ឯកោ ដោះស្រាយវិបត្តិផ្លូវចិត្តតាមបែបអវិជ្ជមាន និងជឹកស្រាលេងល្បែងដើម្បីបំភ្លេចទុក្ខ ។ ប៉ុន្តែ បច្ចុប្បន្ននេះគាត់មានអារម្មណ៍ថាវំកើបណាស់ដែលមានដៃគូពិភាក្សា អាចធ្វើឲ្យគាត់មានអារម្មណ៍ល្អច្រើន ធ្វើឲ្យឈប់ជឹកស្រា និងលេងល្បែងទៀត ។

អ្នកស្រី អ៊ំ យ៉ាន ចង់ឲ្យមានក្រុមពិភាក្សាបែបនេះសម្រាប់ជនរងគ្រោះពីការបង្ខំឲ្យរៀបការ និងការវំលោកបំពានផ្លូវភេទផ្សេងទៀតដែរដើម្បីឲ្យមានការជដែកពិភាក្សា ជួយវំលែកទុក្ខគ្នាឲ្យបានធូរអារម្មណ៍ដូចក្រុមរបស់អ្នកស្រីដែរ ហើយចង់ផ្តាំផ្ញើរទៅពួកគាត់ថា មិនមែនមានតែពួកគាត់ទេដែលបានជួបរឿងបែបនោះ មានមនុស្សជទៃទៀតច្រើនណាស់ សូមក្រោកឈរឡើងដើម្បីដឹកនាំគ្រួសារឲ្យកាន់តែប្រសើរឡើង ។

អ្នកស្រីយល់ថាជីវិតរបស់គាត់សព្វថ្ងៃនេះបានធូរស្រាលប្រសើរជាងមុន ស្វាម៉ីគាត់ក៏មិនប្រើហិង្សាដូចមុន គាត់យល់ដឹងច្រើនពីបញ្ហាយេនខ័រ ។ល។ អ្នកស្រីគិតថានឹងនៅតែខំប្រឹងចែរក្សាសុខភាពដើម្បីបន្ទរស់នៅជួយចែទាំបង្ហាត់បង្រៀនកូនចៅឲ្យចេះស្រឡាញ់គ្នារវាងបងប្អូន សាច់ញាតិ និងខិតខំរកស៊ីដើម្បីអនាគតកូនៗរបស់ពួកគេ ហើយពេលចាស់ជាងនេះបន្ថិចទៀតគាត់នឹងទៅវត្តអារាមដើម្បីធ្វើបុណ្យ សន្សំកុសលសម្រាប់ជាតិនេះ និងជាតិក្រោយៗទៀត ។

Ms. OM Yan

Ms. OM Yan, 56, lives in Khna Toteoung village, Khna Toteoung commune, Bakan district, Pursat province. She has seven children. One of her daughters has gone to Thailand to work as a (casual laborer). Four of her children are married and live in the same village. Sometimes they illegally go to Thailand to find work such as working in the vegetable farms as they cannot work on their own rice fields due to unexpected rain or dry weather and/or transplanted rice becoming diseased. She is now living with her husband, her youngest son and three grandchildren whose parents have gone to Thailand to work.

Before the Khmer Rouge era (KR era), Ms. Yan lived in Kork Auvlek village, Spean Thmor commune, Kandal Steung district, Kandal province where she did some work in the rice fields. She was also responsible for looking after her brothers and sisters because her mother died when her youngest sister was 3 months old. Towards the end of 1973, when she was twelve years old bombs began to drop like heavy rain on the country. She fled the village with her aunt, her grandmother, her brothers and sisters and with hundreds of other people from her village and the three other villages nearby because they heard that the KR were nearly at their village. As they were fleeing, they met a group of Lon Nol soldiers who rescued them, and accompanied them toThnol Bot, Chamkar Doung, Phnom Penh so that they could be free from KR. Ms. Yan, her brothers and sisters, aunt and grandmother lived there for one year. The family lived intent and earned a living running a small stall at the market. She and her brother were trying to look for some vegetable such as morning-glory and others types of vine leaves used in soup and other types vegetables for her grandmother to sell in order to have some money to buy food. She has been separated from her father since she fled the village because her father was working in the rice fields far from home and was captured by KR. Until this day Ms. Yan doesn't know whether her father is dead or alive. When the KR captured Phnom Penh in April She, her aunt, grandmother, brothers and sisters were evacuated to Bakan, Pursat. She was assigned to work in the women's mobile group were she was required to work very hard in the rice fields, digging the soil to build the dam and clearing the lands for plantations. Ms. Yan was forced by the KR to marry in 1977 at about 7 p.m. in the Khna Toteoung commune hall just after she returned from her work (clearing land for plantations). She was forced to marry alongside 24 other couples. The night of the marriage she was also spied on by KR cadre like other couples. Her husband violently abused her; despite the fact that she was trying to be responsive she was still raped on the first night. They are still together.

Most of the villagers and the neighbors know about her forced marriage because some of them were forcibly married at the same time. Others know because they overheard from others, and some other people heard from her. She spoke about it with some of the villagers and also with her children. Their reactions to her experience of forced marriage were to be expected; they showed empathy to her, except her husband's family who don't value her and never treat her like a daughter -in-law or a sister-in -law. Despite the fact her marriage was arranged and forced upon her by the Khmer Rouge,

the couple still lives with each. Sometimes she feels like living with him is difficult especially in terms of the way he treats her – not accepting her and constantly looking down on her. When she was pregnant with her first child, her husband committed adultery. He often beat her and left her at home without showing any worry or concern about her or the child. Ms. Yan could not do anything but live through it and endure the pain. Once, she tried to hurt herself and attempted to kill herself by taking pesticide, but she was rescued. Ms. Yan has a very good and close relationship with all of her children. They love her as much as she loves them but her husband doesn't seem to have a good relationship with them.

Since the war ended, Ms. Yan supported the family with her bare hands working in the rice fields to support her family to eat and live. Her children were unable to finish school because the family finances could not support their continued education. She tries her best to ensure that her youngest son will have a higher education. Nowadays, she is reasonable comfortable compared to the other families in the village because aside from the income she gets from crops she is also supported by her children who are working overseas.

Ms. Yan feels that the war caused her great loss including her father, brothers and sisters, relatives and all the property she had. These losses make her feel sad and lonely. In addition to suffering those losses, she was forced to marry. She continues to suffer from this marriage, and feels that she is not a valuable person and that is why her husband's family does not accept her. Sometimes she thinks about killing herself but it is impossible because she worries a lot about her children and their future life.

Since participating in the self-help group, Ms. Yan feels that she is more relaxed and happy because she has good team members and the facilitator to listen to her difficulties with empathy and understanding. She is especially happy about the helpful comments and feedback she received. The group helps to solve difficulties for everyone, and helps them all to feel relief. She added that her ability to share her sadness and painful experiences with the group, and the group activities, have contributed to 70-80% of her mental and emotional healing. She liked some of the group activities including the drawing and painting of a tree which represents the self, building a grave for her father to rest by playing with sand. She also enjoyed other exercises and activities that involved thinking about leadership and team spirits. Ms. Yan will continue to meet her group members, who can support each other given that they shared the same painful memories of the KR. They will visit each other more often. She thinks that forming a group of people who share similar experiences like this is good and helpful;

they can feel comfortable to share and feel better. Before joining the group, Ms. Yan, saw herself as a lonely person who dealt with stress in a negative way by drinking alcohol and gambling. But now she feels excited by the fact that when she is stressed she turns to find a friend (especially the team member) to talk to. This makes her feels a lot better and has helped her to stop drinking and gambling.

Ms. Yan wants to have more of these groups for other survivors of forced marriage and sexual abuse so that these survivors may have people to share their pain with, like she has had with her group. She wants them to know that forced marriage and rape happened to many other women during war, not only them but many other people. She wants to tell them to please be strong and lead their family (forproperties.)

Ms. Yan feels that her life is a lot better now. Furthermore, her husband does not beat her like before and he knows more about gender issues etc. Ms. Yan think that she will continue to take care of her health to live better to advise and teach her children and her grandchildren to love each other, to love their relatives and to try their best to earn for the future of their children. When she gets older she is going to go to pagodas more often to save good karma for this life and her next lives

រី ហុន អ្នកស្រី រី ហុន អាយុ៥៨ឆ្នាំ រស់នៅភូមិដើមការ ឃុំខ្នារទទឹង ស្រុកបាកាន ខេត្តពោធិសាត់ ។ ត្រួសារអ្នកស្រីជាត្រួសារដែលក្រីក្រចំផុតក្នុងភូមិ គ្មានដីស្រែចំការ និងគេសូម្បីតែផ្ទះខ្នមតូចមួយក៏សង់លើដីរបស់បងថ្លៃដែរ ។ អ្នកស្រីមានកូន ៥នាក់ ស្រី៣នាក់ និងប្រុស២នាក់ ប៉ុន្តែកូន៧ច្បងទាំង៣នាក់ បានទៅស៊ីឈ្នួលធ្វើកម្មករនៅប្រទេសថៃ ឯកូនម្នាក់ទៀត បានរៀបការមានត្រួសារផ្ទាល់ខ្លួនគេហើយ ។ សព្វថ្ងៃ អ្នកស្រីរស់នៅជាមួយប្តី និងកូនស្រីពៅអាយុ១៣ឆ្នាំដែលកំពុងនៅរៀនថ្នាក់ ៨ គាត់ប្រកបរបរស៊ីឈ្នួលជកស្លុងនៅពេលដែលអ្នកភូមិត្រូវការ ។

មុនសម័យខ្មែរក្រហមអ្នកស្រី ជាកុមារីដែលមិនបានទៅសាលារៀនស្ទុះនឹងគេទេ ដោយសារជីវភាពក្រីក្ររស់នៅជាមួយម្តាយជាស្ត្រីមេម៉ាយ ខំប្រឹងជួយធ្វើការងារផ្ទះ និងធ្វើស្រែចំការ រស់នៅក្នុងភូមិខ្នារទទឹងនេះ ។ នៅក្នុងសម័យខ្មែរក្រហមគាត់ និងត្រួសារត្រូវបានគេជម្លៀសទៅភូមិត្រពាំងអណ្តែង ចម្ងាយប្រហែល ១០គ.ម ពីភូមិខ្នារទទឹង ។ គាត់មានវ័យ ១៥ឆ្នាំ ស្ថិតនៅក្នុងកងនារី ធ្វើការងារជកស្លុង លើកភ្លឺស្រែ និងជីកប្រឡាយមានពេលសម្រាកប្រហែលជា ៤ ម៉ោងប៉ុណ្ណោះក្នុងមួយថ្ងៃៗ (យប់ខ្លះដេកបានត្រឹមតែ ២ម៉ោងប៉ុណ្ណោះ) ។

អ្នកស្រីត្រូវបានខ្មែរក្រហមបង្ខំឲ្យរៀបការក្នុងខែពិសាខ ឆ្នាំ១៩៧៧ ម៉ោងប្រហែល ៨ល្ងាច ក្នុងវ័យ ១៧ឆ្នាំ ជាមួយ ១៨គូផ្សេងទៀតក្នុងពេលតែមួយ ។ ពេលនោះគាត់មិនទាន់ពេញវ័យគ្រប់ការនៅឡើយទេ ។ ប្តីរបស់គាត់ស្នើទៅមេកងសុំរៀបត្រួសារជាមួយគាត់។ ប្តីគាត់ត្រូវជាបងជីដូនមួយនឹងគាត់ដែលធ្លាប់ឃុសរៀនជាសង្ឃពីមុនសម័យខ្មែរក្រហម ។ ទោះជាមានការឃ្លាំមើលពីឈ្លបក៏ដោយ អ្នកស្រីបានរួចខ្លួនមិនរួមដំណេកវាយតដល់ចុងឆ្នាំ ១៩៧៨ ដោយសារពេលនោះប្តីអ្នកស្រីអនុគ្រោះជួយបន្លំ លាក់លៀមនឹងឈ្លបមកវាយតដែរ ។ ការរួមដំណេកជាមួយប្តីរបស់គាត់គឺជាការព្រមព្រៀង ដោយសារតែគាត់ពេលនោះបានចាប់ផ្តើមមានអារម្មណ៍ស្រឡាញ់ប្តីដោយសារអំពើល្អរបស់គាត់ ប៉ុន្តែគាត់មិនមានសំណាងរស់នៅជាមួយប្តីរហូតដល់សព្វថ្ងៃនេះទេ ។ នៅពេលបែកខ្មែរក្រហមឆ្នាំ ១៩៧៩ ដោយសារស្តាប់តាមម្តាយគាត់ក៏បានបែកគ្នាពីអ្នកស្រី ។ ពេលគាត់បានត្រឡប់មករកអ្នកស្រីវិញ អ្នកស្រីក៏បានរៀបការថ្មីទៀតរួចទៅហើយកាលពីឆ្នាំ ១៩៨១ ។ បន្ទាប់មកអតីតប្តីរបស់អ្នកស្រីក៏បានរៀបការទៀតដែរ ហើយសព្វថ្ងៃគាត់រស់នៅក្នុងភូមិក្បែរគ្នាដែរ ។

"ទៅពេលដែលមានអំពើហិង្សាកើតឡើងក្នុងក្រុសារបស់ខ្ញុំ ម្តង ៣ បង ៣ ប្អូន ៣ ទាំងអស់បានទៅស្វរស្ថនទុក្ខ តាំទ្រខ្ញុំ លើកទឹកចិត្តខ្ញុំមិនឲ្យខ្ញុំគិតខ្លីចង់សម្លាប់ខ្លួនជួយនិយាយពន្យល់ណែនាំប្តីរបស់ខ្ញុំ"

"ភ្លាកម្មខ្ញុំ ។ មិនដឹងថាជាតិមុនខ្ញុំបានធ្វើអ្វី បានជាជាតិនេះមានកម្មយ៉ាងនេះ" ។

ពួកគាត់មានពេលខ្លះជួបគ្នាដែរប៉ុន្តែមិនស្វរនិយាយរកគ្នាច្រើនប៉ុន្មានទេព្រោះដោយសារតែឆ្លាប់មានអារម្មណ៍ស្រឡាញ់ធ្វើឲ្យអ្នកស្រីនៅមានអារម្មណ៍ខឹងខ្លះដែរដោយសារតែការចុះចេញរបស់គាត់ ។ លើសពីនេះទៀត ប្តីបច្ចុប្បន្នរបស់អ្នកស្រីឆ្លាប់ប្រចឹណ្ឌគាត់នឹងអតីតស្វាមីរហូតដល់មានការប្រើអំពើហិង្សាយ៉ាងធ្ងន់ធ្ងរជាច្រើនដងទៀតផង ។ កូនៗរបស់គាត់ និងអ្នកភូមិក៏បានដឹងថាគាត់ឆ្លាប់ត្រូវបានបង្ខំឲ្យរៀបការសមឹយខ្មែរក្រហមដែរ ហើយពួកគាត់បានសម្តែងការយល់ចិត្តអាណិតដោយសារកាលនោះគាត់នៅក្មេងណាស់ ។ ទំនាក់ទំនងរបស់អ្នកស្រីជាមួយអតីតស្វាមីនៅពេលរស់នៅជាមួយគ្នាក្នុងរយៈពេលដ៏ខ្លីនោះមិនមានបញ្ហាអ្វីទេ ប្តីគាត់ស្រឡាញ់គាត់ គាត់ក៏ស្រឡាញ់ប្តីព្រោះគាត់ជាមនុស្សស្លូតបូត ចិត្តល្អ ដឹងនុសត្រូវ ហើយចេះជួយទុក្ខធុរៈ ។ អ្នកស្រីមិនមានកូនទេពីការបង្ខំឲ្យរៀបការនោះ ។ អ្នកស្រីបាននិយាយថាបើមានកូនពីពេលនោះ នោះយើងក៏ប្រហែលជាបានរស់នៅជាមួយគ្នារហូតដល់សព្វថ្ងៃហើយ ។ អ្នកស្រីមានប្រសាសន៍ថាជីវិតរបស់គាត់ពិតជាអភ័ព្វណាស់ក្នុងជីវិតទាំងមូល ជាពិសេសបន្ទាប់ពីបានរៀបការជាមួយប្តីក្រោយរបស់គាត់នេះ ។ អ្នកស្រីបានរៀបការជាលើកទីពីរ នៅឆ្នាំ ១៩៨១ ។ ចាប់តាំងពីបានកូនទីពាមក ប្តីរបស់អ្នកស្រីបង្កើនការផឹកស្រាមិនធ្វើការងារ ឈ្លោះឆ្នាជាញឹកញាប់ ផេរបញ្ចោ ភាយកំទេចចានឆ្នាំង និងសម្ភារៈក្នុងផ្ទះជាច្រើនទៀត ។ ពេលខ្លះពេលគាត់ទៅស៊ីឈ្នួលគេរកលុយមក ចិញ្ចឹមត្រូសារមកវិញយើញប្តីវៃកូន ចាប់បោះកូនចេញពីលើផ្ទះ ភាយធ្វើបាបគាត់ដល់បែកក្បាលជាច្រើនលើកច្រើនសារ ។ ទោះជាមានអន្តរាគមន៍ពីអជ្ញាធរដែនដី ក៏ប្តីរបស់គាត់មិនកែប្រែដែរ ជួនកាលកែប្រែត្រឹមតែមួយថ្ងៃពីរថ្ងៃ ក៏ត្រឡប់ដូចដើមវិញហើយ ។ អ្នកស្រីឆ្លាប់ស្ទើរស៊ុំលែងលះជាច្រើនដងដែរ ប៉ុន្តែប្តីគាត់មិនព្រម ហើយគាត់ឆ្លាប់មានបំណងរត់ចេញពីផ្ទះជាច្រើនដងឆងដែរ ប៉ុន្តែមិនអាចដោយ សារតែគិតពីកូនស្រីពៅរបស់គាត់ បើយកទៅតាមគេនឹងខាតមិនបានរៀនសូត្រ ប៉ុន្តែបើទុកឲ្យនៅផ្ទះជាមួយឌ្ឋាកនុះ ឌ្ឋាកឲ្យាស់ភាយធ្វើបាបស្លាប់មិនខាន ។ មកដល់បច្ចុប្បន្ននេះ ប្តីគាត់ផឹកស្រាវាល់ថ្ងៃ ដេកនៅផ្ទះមិនចេញដើររកស៊ី ឬក៏ជួយធ្វើកិច្ចការផ្ទះអ្វីបន្តិចទាល់តែសោះ សូម្បីតែឡើងជួសជំបូលផ្ទះដែលរហែកឆ្លុះ ចាំងថ្ងៃ លេចទឹកភ្លៀងក៏សុទ្ធតែជាការងាររបស់អ្នកស្រីដែរ ។ ចាប់តាំងពីសង្ត្រាមចប់មករហូតដល់សព្វថ្ងៃអ្នកស្រី ប្រកបរបរស៊ីឈ្នួលដក ស្ទូង ច្រូត កាច់ពោត ដកដំឡូងនៅក្នុងភូមិស្រុករបស់គាត់នេះ ដើម្បីទិញអង្ករ និងម្ហូបអាហារតិចតួចប្រចាំថ្ងៃ ។ លើសពីនេះទៅទៀតគាត់នៅមានជាប់ជំពាក់បំណុលគេ ពីងពាក់ទាំងស្រុងតែទៅលើ ប្រាក់តិចតួចដែលកូនឆ្មើមកពីប្រទេសថៃ ដើម្បីសងគេ ។ អ្នកស្រីយល់ថាខ្លួនឯងជាមនុស្សអភ័ព្វណាស់មួយជីវិតនេះ ជាកូនដែលត្រូវ បានឌ្ឋាកបោះបង់ចោលជួបសង្ត្រាម ស្លាប់ម្តាយបងប្អូនមិនបានរៀបការតាមប្រពៃណីដូចគេឯង ប្តីរកលេសប្រចឹណ្ឌ ភាយធ្វើបាប ទាំងផ្លូវកាយផ្លូវចិត្ត និងផ្លូវភេទ ។ ប៉ុន្តែប្រហែលមួយឆ្នាំចុងក្រោយនេះប្តីរបស់គាត់មិនស្វរភាយដំ គាត់ដូចមុនទេ ព្រោះដោយ មានការគាំទ្រផ្តល់កម្លាំងចិត្តពីសមាជិកក្រុមជួយខ្លួនឯងរបស់យើង គាត់អាចមានជំហ៊ីរវិងមាំប្រសើជាងមុនដោយមិនអង្គុយ ឬឈរស្ទៀមឲ្យប្តីភាយទៀតទេ គាត់អាចភាយតបត ឬក៏អាចច្រានប្តីចេញឲ្យឆ្លាយពេលភាយគាត់ ។ គាត់ក៏អាចតបតបានដោយសារ តែប្តីគាត់តែងតែស្រវឹងស្រា មិនមានកម្លាំងខ្លាំងដូចមុនទើបអ្នកស្រីអាចប្រឈមមុខបាន ។ អ្នកស្រីបាននិយាយថាបើមិនមានប្តី ម្លេះជីវិតខ្ញុំ និងកូនៗនឹងប្រសើរជាងនេះ ។ ពេលខ្លះគាត់គិតថាបន់ឲ្យតែប្តីនេះស្លាប់ទៅល្អជាង ។ អ្នកស្រី រ៉ ហុន បាននិយាយទាំងទឹកមុខក្រៀមក្រំថា "ភាជាកម្មខ្ញុំ ។ មិនដឹងថាជាតិមុនខ្ញុំបានធ្វើអ្វី បានជាជាតិនេះមានកម្មយ៉ាងនេះ" ។

អ្នកស្រីពេញចិត្តនឹងទំនាក់ទំនងល្អនៅក្នុងក្រុមណាស់ គាត់បាននិយាយថា "នៅពេលដែលមានអំពើហិង្សាកើតឡើងក្នុងត្រូសារបស់ខ្ញុំម្តង ៣ បង ៣ ប្អូន ៣ ទាំងអស់បានទៅស្វរស្ថនទុក្ខ តាំទ្រខ្ញុំ លើកទឹកចិត្តខ្ញុំមិនឲ្យខ្ញុំគិតខ្លីចង់សម្លាប់ខ្លួនជួយនិយាយពន្យល់ណែនាំប្តីរបស់ខ្ញុំ" ក្រុមទាំងមូល និងសកម្មភាពនានាអាចជួយឲ្យអ្នកស្រីធូរស្រាលក្នុងចិត្តបាន ប៉ុន្តែនៅពេលដែលអ្នកស្រីត្រឡប់ចូលដល់ផ្ទះវិញ ធ្វើឲ្យអ្នកស្រីមានអារម្មណ៍ឈឺចាប់ដដែល ។ សកម្មភាពនានាដែលអ្នកស្រីសប្បាយរីករាយនៅពេលដែលចូលរួមក្នុងជំនួបក្រុមម្តង ៣ មានដូចជាការដើរលេង ការគូររូប ការប្រើដីខ្សាច់ដើម្បីឲ្យ គាត់រំឦកដល់សាច់ញាតិ និងអ្វីដែលបានបាត់បង់នៅសមឹយខ្មែរក្រហម មានអារម្មណ៍ថាដូចជាបានពូនភ្ជំខ្សាច់ ។ អ្នកស្រីគិតថានិងនៅតែបន្តជួបក្រុមតទៅទៀត ព្រោះទាំងអស់ត្មាសុទ្ធតែជាមនុស្សល្អ ស្មោះត្រង់ ស្រឡាញ់ត្មាដោយស្មោះ ហើយនឹងនៅតែឧស្សាហ៍ជួបត្មា និងបន្តរាប់អានគ្នាតទៅទៀត ។ អ្នកស្រីយល់ថាគាំងពីបានចូលរួមជាមួយក្រុមនេះ គាត់មានអារម្មណ៍ជ្រះស្រឡះជាងមុន ការស្មុតស្មាញ

ក៏ថយចុះជាងមុន អាចរឹងមាំជាងមុនហ៊ានក្រោកឈរតតាំងការពារសិទ្ធិរបស់ខ្លួន និងការពារកូនៗ ។ អ្នកស្រីមិនមានពាក្យពេចន៍អ្វី និយាយទៅកាន់ជនរងគ្រោះពីការបង្ខំឲ្យរៀបការនិងការរំលោភផ្លូវភេទ ក្រៅពីពាក្យថារឹងមាំឡើង ក៏មានអ្នកដទៃកើតរឿងដូចយើងដែរ។ ទោះជាយ៉ាងណាអ្នកស្រីយល់ថាសព្វថ្ងៃនេះជីវិតរបស់គាត់ពិបាកណាស់រកពេលវេលាសប្បាយបានតិចតួចណាស់ ពេលចូលដល់ផ្ទះម្តងៗ ជួបមុខប្តីដែលតែងតែដេកស្រវឹងនៅផ្ទះ ធ្វើឲ្យគាត់ខឹងមួរម៉ៅ ចង់តែគេចចេញពីផ្ទះឲ្យបាត់ៗ ប៉ុន្តែគាត់សន្យាថានឹងមិនគិតសម្លាប់ខ្លួនទៀតទេ នៅពេលដែលគាត់ពិបាកចិត្តខ្លាំងនឹងទៅរកសមាជិកក្រុមណាម្នាក់ដែលលេង ជួយរកដំណោះស្រាយ ។ អ្នកស្រីក៏មិនបានគិតថាទៅថ្ងៃអនាគតអ្នកស្រីនឹងធ្វើអ្វីបន្តទៀតដែរ ប្រហែលជាចេញទៅស៊ីឈ្នួលធ្វើកម្មករនៅប្រទេសថៃជាមួយកូនៗ ប៉ុន្តែនៅតែបារម្ភនឹងការសិក្សារបស់កូនស្រីពៅ ។

ឡាយ គីមឈាន រី ហុន អ៊ុំ ង៉ន សន ភាព ឌៀក សំ

រូបថតនៅព្រះបរមរាជវាំង ២០១២

Ms. RY Hon

Ms. RY Hon, 54, lives in Derm Roka village, KhnaToteng commune, Pursat province. Her family is the poorest one in the village because they own nothing. They don't own any land to grow crops on. They live in a small cottage with a thatched roof and thatched walls built on a small piece of land owned by her brother-in law. She has three daughters and two sons.Three of her children illegally left the country and went to Thailand to find jobs. One son is married and lives with his wife and children in another province. Nowadays, she lives with her husband and her youngest daughter who is 13 years old and attends grade 4 at the primary school in the village. She works for somebody who needs help growing crops and harvesting. Her income is irregular, depending on clients and her ability to work.

Her current husband is very jealous of her the relationship she had with her first husband to the extent that he is chronically severely violent towards her.

Before the Khmer Rouge (KR) era she was unable to attend school due to economic problems. She lived in KhnaToteng village in poverty with her mother (a widow) working hard in household and rice field work.

During the KR era, when she was 15 years old, her family was evacuated to Trapang Andeng village, about 10 km from Khna Toteng. She was assigned to work in the women's mobile group who were required to grow and harvest crops, build the canal for agricultural purposes and worked very hard days and nights with only about four hours rest (some nights they could sleep only for two hours before the KR rang the bell to start working again.)

One day in May 1977 at about 4 p.m. she was forced by the KR to get married along with 14 other couples, despite the fact that she had not reached puberty. Although she was 17, she was late to reach puberty due to malnutrition and hard labor. Her husband (who is also her cousin) had been a monk before the KR came to power.,He asked the chief of the cadre in the village if he could marry her.

They were spied on by the KR to see whether they consummated the marriage. Because her husband was a good man trying to lie to and hide from the KR cadre she was able to avoid consummating the union until 1978. Eventually she agreed to sleep with her husband because by then she has begun to love him because he was a good man. Unfortunately, she could not continue to live with her husband up to this day, as after the KR collapsed in early 1979 he was persuaded by his mother to return home and leave her. In 1981, he returned to her with the hope of reuniting, however by them unfortunately Ms. Hon was married to another man. Later, her first husband also remarried and lived in the next village. Occasionally they meet but she doesn't speak to him much because she is still angry that he left her and returned to live with his mother. Furthermore, her current husband is very jealous of the relationship she had with her first husband, to the extent that he is chronically severely violent towards her.

The people of her village and her children know about the story of her forced marriage and they show empathy with her. The relationship between her and her ex-husband was good, he loved her and she also loved him because he was a good man – he knew what was right or wrong and was very helpful. She didn't have any children from the forced marriage. She said if she had children at that time maybe her husband would not have left her and they would live happily together now. She said that her whole life has been very unfortunate, especially since 1981 when she married her second husband. After she gave birth to her third child, her husband stopped doing any work, started drinking more alcohol, fought with the family more often, and cursed her with bad language and smashed the furniture in the house and the kitchen, etc. Sometimes when she returned from her work selling in order to earn a daily living she would see her husband beat and throw her children out of the house. He would also beat her and she was wounded in her head often. Although there were occasions when the local authorities intervened, her husband never changed; after only one or two days following these visits from the local authorities he returned to the same violent behaviour. She asked for a divorce many times but her husband did not agree. She also attempted to run away from home a few time but it was not possible as she could not leave her youngest daughter. If she decided to take her with her then she would have to stop school (which she doesn't want to happen) but if she leaves her with her drunken father, she is worried that he might beat her to death. Nowadays, her husband is drunk every day, always sleeps after drinking, does not work or earn any income, or do anything around the house. Even the job of replacing the old leaking roof and the wall is the job of Ms. Hon.

"It is my bad karma. I don't know what I did in my previous life to deserve this terrible life" said Ms. Hon in with a sad, hopeless face.

Since the war ended, she has worked for other people in their rice and vegetable fields to earn a living (especially enough money to buy food each day). This is because she does not own any land herself to grow vegetables and rice on (before the KR era her father left her mother for another woman and took all the land her mother left to her before she died). Furthermore, she is still in debt as she relies on her children who are working in Thailand to send her money, which she uses to pay her debts. She thinks her whole life has been very unfortunate; she was abandoned by her father, experienced war, her mother, brothers, sisters and relatives died in the war, she was improperly married without any dignity as a woman in accordance with Cambodian traditions, and suffers from physical, emotional and sexual violence because of her husband's jealousy.

However in the last year her husband has not beat her as often and as violently as before, because, with the support she has received from the self-help group members, she has been able to stand up to him and fight back or at least push him away when he begins to beat her

and her daughter. She is also able to fight back because her husband is always drunk and has less strength than before. She said that if she was to live without him, her life and the children's life might be a lot better. Sometimes, she wishes her husband was dead rather than living because of all the difficulties he brings to the family. "It is my bad karma. I don't know what I did in my previous life to deserve this terrible life" said Ms. Hon in with a sad, hopeless face.

She says that "any time my husband beat me, everyone came to visit and support me emotionally, they would encourage me and tell me not to think of suicide and would sometimes talk with my husband to tell him to stop being violent".

She loves the relationship that she has with her self-help group. She says that "any time my husband beat me, everyone came to visit and support me emotionally, they would encourage me and tell me not to think of suicide and would sometimes talk with my husband to tell him to stop being violent". The team and the team activities helped her to release some tension but when she returned home, every tension came back and made her feel pain. Some of the activities that she enjoyed in the meetings were the tour of the city, and painting. She also enjoyed using sand to remind her of her relatives and what she lost in war; she felt as if she was building the sand mountain in the Buddhist ceremony.

She is going to continue meeting her team members more often because they love each other; they are all good and honest people. She said that since she joined this group, she felt better when they met, her levels of stress and tension decrease and, she is able to stand up for her rights and protect her children. She doesn't have much to say to the other survivors of forced marriage and sexual abuse other than they should be stronger, and that there are more people suffering from the same things than you think.

She still thinks that her life is very difficult. She finds very little time to be happy. Any time she returns home and sees her drunken husband asleep like a dead body she feels annoyed and angry. It makes her want to leave home, but she promised the team that she will not think of committing suicide again. When she is highly stressed she will come to meet at least one or two people of the team to share her feelings and get them to help her find the solutions. Ms. Hon is not sure what she is going to do in the future. Maybe she will leave the country to work with her children in Thailand, but she is still worried about her youngest daughter's education.

សន ភាព

អ្នកស្រី សន ភាព អាយុ៩៧ឆ្នាំ ជាស្ត្រីមេម៉ាយរស់នៅភូមិ ស្ទឹងកំបុត ឃុំត្រពាំងជង ស្រុកចាគាន ខេត្តព្រៃវែង ។ អ្នកស្រីមានកូនបង្កើត ៨នាក់ និងកូនចិញ្ចឹមម្នាក់ មានមុខរបរជាកសិករ ធ្វើស្រែចំការ ដាំបន្លែ និងចិញ្ចឹមមាន់ ។ ដោយសារតែជីវភាពខ្វះខាត សព្វថ្ងៃកូនៗ របស់អ្នកស្រីចេញទៅធ្វើកម្មករនៅប្រទេសម៉ាឡេស៊ី និង ប្រទេសថៃដើម្បីរកប្រាក់មកផ្គត់ផ្គង់គ្រួសារ ។

មុនសម័យខ្មែរក្រហម អ្នកស្រីរស់នៅភូមិស្រង់ ឃុំស្រង់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ពេលនោះគាត់ នៅជាកុមារនៅឡើយ ប៉ុន្តែមិនបានរៀនសូត្រទេ គាត់រស់នៅទីនោះតាំងពីតើតរហូតដល់ ១២ឆ្នាំ ទើបក្នុងសម័យខ្មែរក្រហម ឆ្នាំ ១៩៧៥ អ្នកស្រីត្រូវបានគេដង្កៀសជាមួយក្រុមគ្រួសារ ដោយដីរទេះភ្លើងឲ្យមករស់នៅភូមិស្វាយដូនកែវ ឃុំឫស្សីក្រាំង ស្រុកមោង ខេត្តបាត់ដំបង ធ្វើការក្នុងក្រុមកងចល័តទទួលការងារជីកប្រឡាយ ។

ក្នុងឆ្នាំ១៩៧៧ ម៉ោងប្រហែល១២ថ្ងៃត្រង់ បន្ទាប់ពីមកពីជីកប្រឡាយ មានឡានមួយមកដឹកគាត់ និងនារី៨នាក់ទៀត យកទៅរៀនសូត្រនៅគុកឯកភូមិស្វាយព្រះ ខេត្តព្រៃវែងជាមួយអ្នកទោសជាច្រើនទៀត ។ បន្ទាប់ពីដាក់ខ្នោះស្រាប់តែមេកងបានដើរចូលមក ហើយប្រាប់កូនចៅរបស់ គេថាឲ្យដោះលែងគាត់ព្រោះគាត់មិនដឹងអ្វីទេ បន្ទាប់មកអ្នកស្រីក៏ត្រូវបានគេដោះលែងដើរមកស្នាក់នៅក្នុងវត្តធម្មយុត្តិមួយក្នុងភូមិស្វាយព្រះ ។ ស្អែកឡើងអ្នកស្រីត្រូវបានគេហៅម្តងទៀតថាឲ្យទៅរៀនសូត្រ ហើយអ្នកស្រីភ័យស្ទើស្លាប់គិតថាលើកនេះឆ្ការស់ជាស្លាប់មែនទែនហើយលុះទៅដល់គាត់ដឹងថាគេហៅគាត់ទៅឲ្យរៀបការ គាត់ស្រែកយំយ៉ាងខ្លាំងប្រាប់ថាមិនចង់រៀបការទេ ពេលនោះខ្មែរក្រហមបានតំរាមថា "មិត្តឯងចង់ងាប់ឬ?" ។ ដោយការភ័យខ្លាចគាត់ក៏មិនហ៊ានតវ៉ា ក៏ព្រមឲ្យគេរៀបការឲ្យទៅ ។ ពេលអ្នកស្រីរៀបការនោះ មាន ១៩គូ ដែលស្ទូតែជាគូដែលមិនដែលស្គាល់គ្នាពីមុននោះទេ ។ បន្ទាប់ពីយប់រៀបការនោះមក ខ្មែរក្រហមបានហៅប្តី របស់គាត់ទៅសួរនាំថាតើទំនាក់ទង ប្តីប្រពន្ធគាត់យ៉ាងម៉េចដែរ តើប្រពន្ធយល់ព្រមទេ? ប្តីក៏បានប្រាប់ថាមិនអីទេ ។ មកដល់ផ្ទះវិញគាត់បានប្រាប់ប្រពន្ធថាមិនឲ្យនិយាយ ឥវ៉ាអ្វីទាំងអស់ទោះស្រឡាញ់ឬមិនស្រឡាញ់គ្រូវតែរួមរស់ជាមួយគ្នា បើមិនដូច្នេះទេគេនឹងយកពួកគាត់ទៅសម្លាប់ហើយព្រោះគូដែលបាន រៀបការក្នុងថ្ងៃជាមួយគ្នាដទៃទៀតត្រូវបានគេបញ្ជូនចេញពីសហករនោះចាត់អស់ទៅហើយ ។ អ្នកស្រីក៏ព្រមរួមរស់ជាមួយប្តី ដល់ពេលសម្រាលបានកូនស្រីមួយ (ឥឡូវនៅធ្វើកម្មករបម្រើការនៅផ្ទះគេនៅប្រទេសម៉ាឡេស៊ី) ទើបតែបាន បីថ្ងៃ ខ្មែរក្រហមបានចាប់យកប្តីរបស់គាត់ទៅចាត់មិនដឹងទៅណាដោយចោទថាជនក្បត់ ។ ពេលនោះចាប់ផ្តើមឮដំណឹងថាមានទាហានវៀតណាមចូលមកជួយរំដោះបណ្តើរៗ ខ្មែរក្រហមក៏បានប្រកាសប្រាប់ឲ្យប្រជាជនឲ្យរត់ ។ នៅពេលរត់នោះគាត់ដាច់បាយដាច់ទឹកព្រោះ បងថ្លៃស្រីមិនឲ្យហូប ប៉ុន្តែបានម្តាយក្មេកជួយនិយាយដោយយល់ថាគាត់នៅកូនខ្ចីទើបតែសម្រាលកូនបានបីថ្ងៃ ។ ពួកគាត់ចេះតែរត់ចុះមកក្រោមមកដល់ចាកានបន្ទាប់មកក៏បានជួបនិងជួយសង្គ្រោះដោយទាហានវៀតណាមហើយក្រោយមកក្នុងឆ្នាំដដែលនោះគាត់ក៏បានជួប ជុំជាមួយប្តីវិញព្រោះប្តីគាត់បានរួចពីការសម្លាប់ពីសំណាក់ទាហានខ្មែរក្រហមដោយសារបានកងទ័ពវៀតណាមមកជួយទាន់ ។ ក្រោយ របបខ្មែរក្រហមប្តីរបស់គាត់បានធ្វើជាគ្រូបង្រៀនម្នាក់ ។

នៅឆ្នាំ ១៩៩០ នៅពេលដែលអ្នកស្រីមានថ្ងៃពោះកូនទី ៨ ប្តីរបស់គាត់ក៏បានចុះ ចេញពីផ្ទះទាំងខណៈពេលដែលប្រពន្ធជិតគ្រប់ខែសម្រាលកូនទៅជាមួយប្រពន្ធចុង ។ រឿងដល់រឿងនេះធ្វើឲ្យគាត់ឈឺចាប់យ៉ាងខ្លាំងគាត់យល់ថា ហេតុអ្វីគេមិនឆ្ងល់ចាំដល់កូនកើតរួចសិនបើទោះបីជាគាត់បានអង្វរប្តីក៏ដោយ ។ អ្នកស្រីមិនសុខចិត្តរឿងក្បត់ឬ និយាយរឿងបង្ខំឲ្យរៀបការនោះទេជាពិសេសជាមួយអ្នកភូមិ

ពីព្រោះគាត់មានអារម្មណ៍ថាខ្មាស់គេ គាត់មានអារម្មណ៍ថាអាណិតកូនៗ គាត់ដោយពួកគេមានឈ្មោះថា ជាកូនឥតខាន់ស្លារ ។ អ្នកស្រីបានក្លាយជាស្ត្រីមេម៉ាយតាំងពីពេលនោះមក ដោយមិនសម្រេចចិត្តរៀបការជាលើកទីពីរទៀតទេ ពីព្រោះ គាត់ភ័យខ្លាចបើរៀបការទៀតប្តីក្រោយអាចធ្វើបាបកូនៗ ហើយម្យ៉ាងទៀតយល់ថាខ្លួនឯងក្រីក្រ មិនអាចផ្គត់ផ្គង់ត្រូសារបាន ។ ទំនាក់ទំនងរបស់អ្នកស្រីនឹងកូនៗល្អ នឹងគ្នាណាស់ ពួកគេទាំងអស់គ្នាតែងតែចារម្ចខ្ទល់ខ្ទាយពីម្តាយជួយការងារ និងយល់ទុក្ខធុរៈម្តាយ ។

ចាប់តាំងពីសង្ក្រាមចប់មកអ្នកស្រីនិងកូនៗប្រកបរបរធ្វើស្រែ ជាំជំណាំតិចតួច ភ្ជួរាស់ ជកស្ទូងទទួលបន្ទុកចិញ្ចឹមកូនតែម្នាក់ឯង ស៊ីឈ្នួលគេ ជកស្ទូងជើម្បីរកប្រាក់ចិញ្ចឹមកូន ប្តីតែងមានប្រពន្ធចុងខាងក្រៅមិនសូវចូលផ្ទះធ្វើឲ្យគាត់កាន់តែឈឺចិត្តថែមទៀត ទីបំផុតប្តីឈឺជិតស្លាប់ គ្មាននរណាថែទាំ និងធ្វើបុណ្យឲ្យក៏បានត្រឡប់មកវិញឲ្យគាត់និងកូនៗធ្វើបុណ្យឲ្យ ។ អ្នកស្រីរស់នៅប្រកបដោយការឈឺចាប់ដោយសារប្តីធ្វើបាបចិត្ត ម្តាយក្មេក និងបងថ្លៃ មើលងាយ រើសអើងមិនរាប់រក ។ អ្នកស្រីធ្លាប់គិតថាខ្លួនឯងគ្មានតម្លៃ មិនស្គាល់ការសប្បាយមានអារម្មណ៍ថាស្តាយក្រោយចំពោះអ្វីដែលបានកើតឡើងចំពោះជីវិតរបស់គាត់ ។ សព្វថ្ងៃបើទោះជាអ្នកស្រីក្រីក្រ ប៉ុន្តែបើប្រៀបធៀបជាមួយពីមុនវិញគឺ បានប្រសើជាងមុន ឯទំនាក់ទំនងជាមួយសហគមន៍ក៏ប្រសើរជាងមុនដែរ ។

សន ភាព: កន្លែងដែលគាត់ចង់ទៅ នៅពេលដែលគាត់ចាស់

Sorn Pheap: Place she want to go when she gets older.

អ្នកស្រី សន ភាព យល់ថាក្រុមជួយខ្លួនឯងទាំង ៨នាក់របស់គាត់ជាក្រុមជាក្រុមល្អ ស្មោះត្រង់ ជឿជាក់គ្នា ចេះស្រឡាញ់គ្នាជូចបងប្អូន ក្រុមនេះក៏បានរួមចំណែកយ៉ាងច្រើន ជួយបំបាត់ភាពនឿយហត់របស់គាត់ ធ្វើឲ្យគាត់សប្បាយចិត្ត មានឱកាសបានរំឲ្យកពីកុមារភាពពីប្រវត្តិឈឺចាប់ និងមានសមាជិកជួយគាំទ្រឲ្យយោបល់កុំឲ្យគិតស្មុគស្មាញច្រើន ជាពិសេសធ្វើឲ្យគាត់មានអារម្មណ៍ល្អ ។ សកម្មភាពដែលអ្នកស្រីចូលចិត្តមានជូចជា ការហូបបាយជុំគ្នា សម្រាកជុំគ្នា គូររូប សម្តែង លំហាត់សម្រាកកាយ និងការពិភាក្សាគ្នា ។ គាត់គិតថានឹងនៅតែបន្តជួយគាំទ្រគ្នាតទៅទៀតដោយសារពួកគាត់បាននិយាយគ្នាហើយថាបើទោះបីជា ស៊ី.ខ.ភ៊ ឈប់ជួយគាំទ្រគាត់ក៏ពួកគាត់នៅតែបន្តរាប់អានគ្នាទៀតដែរ ។ ពួកគាត់នឹងមកលេងសួរសុខទុក្ខគ្នាឲ្យបានញឹកញាប់ ជាពិសេសបើមានរវល់ការ ឬបុណ្យនឹងមកជួយគ្នាឲ្យអស់ពីចិត្តតែម្តង ។ អ្នកស្រីគិតថាការចងក្រងក្រុមរវាងអ្នកដែលមានបទពិសោធន៍ឈឺចាប់ស្រដៀងគ្នាបែបនេះមានប្រយោជន៍ណាស់ ព្រោះធ្វើឲ្យពួកគាត់មិនសូវពិបាកចិត្តដោយបានចែករំលែកអារម្មណ៍ ស្គាប់គ្នាទៅវិញទៅមក មិនសូវមានអារម្មណ៍ឯកោជូចមុនទេ ។ ពីមុនចូលរួមក្រុមអ្នកស្រីយល់ថាខ្លួនជាមនុស្សម្នាក់មិនដឹងពីអ្វីទាំងអស់ មិនសូវមានគោប់រក ប៉ុន្តែឥឡូវគាត់សប្បាយចិត្តច្រើន មានទំនាក់ទំនងល្អជាងមុន មានមនុស្សជួយដោះស្រាយបញ្ហា ដែលធ្វើឲ្យគាត់មិនសូវគិតច្រើន ស្មុគស្មាញជូចមុន ។ អ្នកស្រីចង់ជ្នាំធ្វើទៅកាន់ជនរងគ្រោះពិការបង្ខំឲ្យ រៀបការ និងការរំលោភបំពានផ្លូវភេទផ្សេងទៀតថាឲ្យខំតស៊ូឡើងដើម្បីជីវិតខ្លួន និងកូនៗ សូមកុំគិតខ្លីគូរតែខិតខំតស៊ូជំនះឧបសគ្គ ។

អ្នកស្រីពេញចិត្តនឹងជីវិតរបស់គាត់សព្វថ្ងៃនេះ ថ្វីត្បិតតែក្រប៉ុន្តែមិនសូវពិបាកចិត្តជូចមុន ពីព្រោះគាត់បានឃើញកូនៗរបស់គាត់ ជាកូនប្រកបដោយគន្លងធម៌ និងកត្តញ្ញូចំពោះគាត់ ។ គាត់គិតថាទៅអនាគតគាត់នឹងនៅតែបន្តជាំបន្លែរនៅក្សែរផ្ទះចិញ្ចឹមមាន់ និងទៅវត្តធ្វើបុណ្យទាន ។

Ms. SORN Pheap

Ms. Sorn Pheap, 57, is a widow living in Steung Kambot village, Trapang Chorng commune, Bakan district, Pursat province. Ms. Pheap is a peasant (who grows crops and vegetable sand keeps animals) with four children and one adopted child. Poverty has forced her to allow her children to leave home and seek work in Thailand and Malaysia..

Before the Khmer Rouge era, Ms. Pheap lived in her home town of Sronge village, Sronge commune, Kong Pisei district, Kampong Speu province. She was about 12 years old when the Khmer Rouge (KR) took power. Ms. Pheap did not go to school. When Pol Pot came to power, she and her family were evacuated (by train) to Svay Doun Keo village, Russey Krang commune, Moung Russey district, Battambang province where she was required to work in a mobile team who were responsible for building a canal.

One day in 1977 when she returned from digging the canal at around 12 o'clock she was handcuffed and put in a car with other four women destined for correction in jail in Snam Preah village, Pursat province. Suddenly, the chief of the cadre appeared and ordered the KR cadre to release her on the basis that she was innocent. Ms. Pheap then walked to find refuge at a pagoda in Snam Prash village. The next day, she was called to attend reeducation. Ms. Pheap was scared to death thinking that she was out of luck and would be killed this time. When she arrived, however, she was told that she must marry. Ms. Pheap cried out her refusal. The KR cadre then threatened her saying "Don't you want to live?"

Ms. Pheap was scared to death thinking that she was out of luck and would be killed this time.

Too afraid to refuse the KR's orders again, Ms. Pheap allowed it to happen. There were 19 couples married at the same time. Like Ms. Pheap, none of the couples knew each other. After the forced marriage took place, her husband was questioned by the KR cadre regarding whether Ms. Pheap had agreed to consummate the union. Her husband responded "yes". Her husband returned and told Ms. Pheap not to refuse to do anything ordered by the organization. They had to consummate the marriage and be a real husband and wife, despite the fact that she did not like her husband at all. For her survival she had to marry because other couples that were married the same night were taken away from the cooperative because they did not get along with their partners. Ms. Pheap agreed to consummate her marriage and they lived as husband and wife. Three days after she gave birth to her first child (this daughter is now working in Malaysia as a maid for a Malaysian family) her husband was arrested by the KR who accused him of betraying Angkar. He never returned. Not long after this, news circulated that they were under attack from Vietnam soldiers and the KR cadre told people to run. Ms. Pheap, who had not yet fully recovered from giving birth, travelled by foot with her sister in-law, mother in-law and her few days old baby. On the way, her sister-in law did not give her any food or water. Luckily, her mother in-law helped her and she had water to drink. When they reached Bakan district they met Vietnamese soldiers who rescued them from the KR. Later, in the same year, she met her husband who she thought had been killed. She found out that her husband had also been rescued by Vietnamese soldiers after being taken away by the KR cadre to be killed.

After the KR era, her husband became a school teacher. In 1990, her husband left her for another woman just before she was due to give birth to her fourth child. Ms. Pheap still finds talking about this particularly painful. To this day she does not understand why her husband did not wait until after she had delivered the baby, despite the fact she begged him to wait. Ms. Pheap feels ashamed talking to others (especially her neighbors) or being reminded about her experience of forced marriage. She feels she had shamed her children by failing to marry a good man. After her husband left her she raised her four children by herself. She has never thought of getting married again as she's afraid that a new man might hurt her and her children. Her children take good care of her and work hard to help ease her heavy responsibilities.

She would like to tell other people who have suffered from forced marriage and sexual abuse to stand up for the sake of themselves and their children, and not to ever think about killing themselves.

Since the end of war, Ms. Pheap and her children have made a living by planting rice, growing vegetables, keeping animals and working for other people. She has worked twice as hard in order to raise her children on her own. Her husband often lived outside her home with his new girlfriend, which caused Ms. Pheap great pain. Her husband eventually became ill and when none of his girlfriends would look after him he returned home to her. Ms. Pheap looked after him until he passed away and paid for his funeral. She lived her life in tremendous pain, degraded and under pressure from her sister in-law and mother in-law plus and suffering the hurt that her husband caused her. She had thought that her life was full of unhappiness and she felt worthless and regretful.

Ms. Pheap thinks of the members of her self-help group as honest, supportive and helpful people. The group members' relationship with one another is like that of a brother and sister. Ms. Pheap feels that the self-help group has helped to lessen her mental burdens. She feels happy and supported being able to express herself in a safe environment and talk about her childhood and painful memories. She loves the self-help group activities such as communal meals, drawing, resting together, performing art, doing relaxation exercises, and the group discussions. The members of the group talked and all agreed asa team that they would continue to meet in order to provide support to each other after the CDP program ended. They to plan to pay a visit to each other's home and meet each other at different social events.

Ms. Pheap believes that the establishment of a self-help group for people who have suffered from similar experiences to her has been an effective way for her to reduce the mental distress and loneliness she suffers. Additionally, groups like hers allows members to share their feelings and listen to each other. She used to think that she was stupid and not liked by other people. Now she recognizes that there are people who understand her and can help her solve her problem. She would like to tell other people who have suffered from forced marriage and sexual abuse to stand up for the sake of themselves and their children, and not to ever think about killing themselves. Although she is poor, she is happy with her life now, particularly compared to when her husband was having an affair. She's happy because she has good children who take good care of her. Ms. Pheap says that she will continue to grow vegetables, keep chickens and go to the pagoda on a regular basis.

អ្នកជំពូក

អ្នកនិពន្ធ អ្នកស្រី យឹម សុធារី ជាអ្នកចិត្តវិទ្យាគ្លីនិក និង ជាអ្នកព្យាបាលការប៉ះទង្គិចផ្លូវចិត្ត ។ គាត់បានចូលរួមប្រឡូកក្នុងការងារជាបុគ្គលិកសង្គមកិច្ច និងពិគ្រោះបញ្ហានេះអស់រយៈពេល៨ឆ្នាំមកហើយ ។ អ្នកស្រីបានអនុវត្តសកម្មភាពជាច្រើន ដែលជាការរួមចំណែកក្នុងការលើកកម្ពស់វិស័យចិត្តវិទ្យា និងតម្រូវការរបស់វាក្នុងសង្គមកម្ពុជា ។ គាត់មានបទពិសោធន៍ក្នុងជំនាញអាជីពរបស់គាត់យ៉ាងច្រើនជាមួយនឹងជនរងគ្រោះដោយសារការប៉ះទង្គិចផ្លូវចិត្តពីសម័យខ្មែរក្រហម ។ ប៉ុន្មានឆ្នាំចុងក្រោយនេះការងាររបស់គាត់ផ្តោតជាពិសេសលើអំពើហិង្សាផ្លូវភេទដែលបានកើតឡើងក្នុងសម័យខ្មែរក្រហម ។ អ្នកស្រី សុធារី បានទទួលបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកចិត្តវិទ្យាគ្លីនិក និងការព្យាបាលការប៉ះទង្គិចផ្លូវចិត្ត ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញនៅឆ្នាំ ២០១០ ។ ទន្ទឹមនឹងនោះដែរ អ្នកស្រី សុធារី ក៏បានចូលរួមវគ្គបណ្តុះបណ្តាលថ្នាក់អន្តរជាតិមួយចំនួនស្តីពីសិទ្ធិមនុស្ស និងសន្តិភាពក្នុងបណ្តាប្រទេសដែលឆ្លាប់កើតជម្លោះ /សង្គ្រាម ឃុត្តិធម៌អន្តរកាលក្នុងបរិបទនៃបណ្តាប្រទេសដែលឆ្លាប់មានសង្គ្រាមការព្យាបាលការប៉ះទង្គិចផ្លូវចិត្ត តាមវិធីព្យាបាលថ្មីបែប EMDR។ល។ ដោយមានការអនុវត្តការប្រើប្រាស់ការព្យាបាល រួមទាំងបានទទួលការត្រួតពិនិត្យតាមដានលើការអនុវត្តជាច្រើននោះ អ្នកស្រីបានទទួលសិទ្ធិពីសមាគម EMDR-អឺរ៉ុប ឲ្យធ្វើជាអ្នកព្យាបាល និងជាអ្នកត្រួតពិនិត្យតាមដានលើការអនុវត្តរបស់អ្នកព្យាបាលជំទៃទៀត ដែលប្រើប្រាស់ការព្យាបាលតាមបែប EMDR នេះ ។

Author

Sotheary YIM is a Clinical Psychologist and trauma therapist with eight years of experience working in social development sector in Cambodia. She has been socially engaged in bringing attention to psychology and its need in Cambodian society. Sotheary has extensive professional experience with survivors of trauma from Khmer Rouge era. Recently, her work focuses specifically on the Gender-based Violence during the KR. Sotheary received her master. degree in Clinical Psychology and Trauma Treatment in 2010 from Royal University of Phnom Penh (RUPP) and holds serveral others international training qualification: Human Right and Peace in the Post-conflict countries; Transitional Justice in the context of post-conflict countriesl; Psycho-traumatology and Trauma Treatment and EMDR (Eyes Movement Desensitization and Reprocessing) etc. With extensive professional practice and supervision, Sotheary received the EMDR licensed (EMDR practitioner and supervisor) from EMDR- Europe.

ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា
CAMBODIAN DEFENDERS PROJECT

medica mondiale